# សៀវភៅគតិលោក
# ភាគ ទី១



សុត្តន្តប្រីជា ឥន្ទ

១៨៥៩ - ១៩២៤

ChanBoKeo.com

# ប្រវត្តិពង្សាវតារ

ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ កំណើតកើតនៅស្រុកទន្លេធំគឺភូមិរកា
កោងខេត្តមុខកំពូលមាតាឈ្មោះយាយ មុំ បិតាឈ្មោះបញ្ញងកែ
ឧកញ៉ាកើតថ្ងៃចន្ទខែអាសាធឆ្នាំរកពុទ្ធសករាជកន្លងទៅបាន
២៤០៣ វស្សាគឺថ្ងៃ២២ សុរយតឆ្នាំ១៨៥៩, កាលអាយ១០ឆ្នាំ
នៅវត្តសិក្សាអក្សរខ្មែរ អាយុ១៥ឆ្នាំចេញរៀនប្រែព្រះបរិ
យត្តិបួសជាសាមណេរណៅវត្តព្រែកពោធិ៍បួសបាន១ វស្សាសឹក
ចាកភេទជាសាមណេរ រួចទៅរៀននឹងលោកព្រះអាចារ្យពេជ
ស្រុកព្រះត្រពាំង, អាយុ១៨ឆ្នាំទៅរៀននឹងលោកគ្រូព្រះពុទ្ធ
ឃោសាចារ្យ ប្រាក់ វត្តឧណ្ណាលោម ក្រុងភ្នំពេញ, អាយុ១៩ឆ្នាំ
ទៅរៀននឹងលោកគ្រូព្រះអាចារ្យ សុខ វត្តកែវ ស្រុកបាត់ដំ
បង, អាយុ២០ឆ្នាំបានបួសជាភិក្ខុនៅវត្តកែវ១ វស្សាទើបលា
ព្រះឧបជ្ឈាយាចារ្យទៅរៀននៅស្រុកបាងកកក្រុងស្យាម
រៀនបាន៧វស្សា ក៏វិលមកស្រុកខ្មែរវិញក្នុងអំណាចលោក
ព្រះយ៉ាថាថន (ញ៉ុញ) នៅវត្តកណ្ដាលស្រុកបាត់ដំបង រួមបាន
១០វស្សាលាសិក្ខាបងសឹកមកមានបុត្រភរិយានៅភូមិផ្ទាំធំ លោក
កថាថន (ឈុំ) ចិញ្ចឹមជាទីព្លួងវិចិត្រទោហារបាន តែងបានប្រែ



បាលីជាសម្រាយមានឈ្មោះ៤៤ ឈ្មោះជាសៀវភៅខ្លះ ចារស្លឹក
រឹតខ្លះ, លុះអាយុបាន៥៥ឆ្នាំ រាជការក្រុងភ្នំពេញ ឲ្យយកមកតាំ
ងទីជា ឧកញ៉ាសុត្តន្តប្រីជា ប្រោសឲ្យជួយតែងសព្វវចនាធិប្បាយ
ខ្មែរ នៅទីសាលាបាលី ក្នុងរវាងអាយុ៥៥ឆ្នាំ ដល់អាយុ៦៥ឆ្នាំ
បានលារាជការ វិលមកនៅស្រុកបាត់ដំបងដើមវិញលុះនៅថ្ងៃ
១០កើត ខែអស្សុជ ឆ្នាំជូតឆស័កមានរោគអ្នក បណ្ដាកូនចៅ
រាល់គ្នាប្រតិបត្តិប្រកបថ្នាំរកគ្រូរក្សាពុំចេះធូរទ្បើយ, លុះដល់
ថ្ងៃអាទិត្យ ១២កើត ខែកត្តិក ឆ្នាំជូតឆស័ក ក៏ទទួលអនិច្ចកម្ម
នៅវេលាម៉ោង ៨ព្រឹកគឺថ្ងៃ៨ ណូវឹម ឆ្នាំ១៩២៤ ។

---

(គ) ឆ្លើយថា សត្វលោកទាំងពួងដែលនឹងកើតនោះអាស្រ័យ ដោយបុញ្ញាភិសង្ខារខ្លះ តែបំណែកខាងមនុស្សលោកនេះ ប្រកប ដោយអារម្មណ៍ដែលជាឧតុនិយម និងពីជនិយមនិងកម្មនិយម៣ ប្រការផងគ្នា ។

ឧតុនិយមនោះ បានខាងឯរបស់ធាតុ គឺជាតិដីថ្មីក្រួសរវាន ផ្សេងៗ ។

ពីជនិយមនោះ បានខាងរុក្ខជាតិតិណជាតិស្មៅវល្លិផ្សេង ។

កម្មនិយមនោះ បានខាងឯបសាទរូបដែលជ្រួតជ្រាបទៅ ក្នុងកាយសត្វជាដើម ព្រមទាំងវេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងទ្វារទាំង៦ រួមអារម្មណ៍៣ ប្រការនេះផ្សំ ចូលគ្នាជារាងកាយ ទើបបានជាសត្វទាំងពួងក្នុងមនុស្សលោក ។

ឯចំណែកខាងទេវលោកនោះ មានតែអារម្មណ៍ដែលជាផល នៃកម្មម្យ៉ាងគឺឧបបាតិកៈកំណើត. ១ទៀតឯផែនដីដែលជាទី អាស្រ័យនៅរបស់សត្វនិងរាងកាយរបស់សត្វ និងសារពើទាំង ពួងក៏កើតអំពីកម្មនិយមទាំងអស់ ។ មនុស្សលោកជាហេតុ ទេវលោកជាផលសំរាប់ក្តីរស់នៅរបស់លោកទិព្វ ។

ទេវលោកជាហេតុ មនុស្សលោកជាផលសំរាប់ក្តីរស់នៅ



របស់លោកមនុស្ស ។

(ស) សួរថា សត្វលោកដែលកើតមកជាមនុស្សយើង ហេតុ អ្វីក៏ខុសគ្នា? ។

(គ) ឆ្លើយថា ការដែលប្លែកគ្នានោះព្រោះសង្ខារតាក់តែង ដោយអំណាចបុណ្យនិងបាប ដែលសត្វកសាងមកអំពីបុព្វជាតិ សត្វទាំងឡាយបណ្តាដែលមានចិត្តគ្រប់គ្រងនៅជាដើមនេះ ក៏ ជាធម៌និងលោកផ្សំគ្នាដូចយ៉ាងធាតុទង់ហ្វ៊ា ដែលជារបស់កើត អំពីធាតុមាសនិងទង់ដែងផ្សំគ្នាដូច្នោះ សត្វទាំងឡាយផ្សេងគ្នា ក៏ព្រោះធម៌និងលោកដែលផ្សំគ្នានោះ មានចំណែកតិចច្រើន ផ្សេងគ្នា ដូចយ៉ាងសាច់ទង់ហ្វ៊ាដែលផ្សេងគ្នាព្រោះធាតុទង់ ដែងដែលផ្សំគ្នានិងធាតុមាសនោះ តិចច្រើនជាងគ្នាយ៉ាងនោះ ឯង ចូលចិត្តឬទេ បើពុំចូលចិត្តយើងនឹងញែកកាយញែកចិត្ត ចេញ ជាលោកជាធម៌ឲ្យយល់ក្នុងកាលឥឡូវនេះ ។

(ស) ករុណា ពុំទាន់ចូលចិត្តសព្វគ្រប់ទេ និមន្តលោកគ្រូម្ចាស់ ញែកឲ្យទានស្តាប់បាន ។

(គ) អើឯងចាំស្តាប់ហ្ន៎ ពណ៌លឿងៗដែលឆ្លុះទៅក្នុងសាច់ ទង់ហ្វ៊ានោះ ជាជាតិមាសពណ៌ក្រហមមួយៗក្នុងសាច់ទង់ហ្វ៊ានោះ

ជាជាតិទង់ដែងមានឧបមាយ៉ាងណាចិត្តរបស់សត្វដែលមានសេចក្ដីចេះដឹងនោះជាតិធំ ឯកាយឬអារម្មណ៍របស់សត្វដែលប្រាសចាកក្ដីចេះដឹងនោះ ជាជាតិលោកសេចក្ដីនោះមានឧបមេយ្យដូច្នេះឯង ចិត្តនេះជាជាតិធំ ទើបពុំស្លាប់តែកាយឬអារម្មណ៍ជាជាតិលោក ទើបត្រូវស្លាប់ជាធម្មតា មាសបរិសុទ្ធក្នុងសាច់ទងហ្វ៊ានោះ ពុំមែនទង់ហ្វ៊ា គឺជាមាសចំណែក១ ផ្សេង ដូចគ្នាយ៉ាងនោះឯង ហេតុនោះទើបសត្វលោកកើតឡើងខុសគ្នាដោយអំណាចផ្សំធាតុ គឺបុញ្ញាផិសង្ខារដែលជាបុណ្យនិងអបុញ្ញាភិសង្ខារដែលជាបាប ។

(ស) ករុណាលោកគ្រូអធិប្បាយមកនេះ ក៏ចូលជាគតិធម៌ច្រើនៗ ខ្ញុំព្រះករុណាស្ដាប់បានហើយ តែខ្ញុំព្រះករុណាត្រូវការចង់ដឹងចង់ចេះតែក្នុងគតិលោក ចំណែក១ សូមទានអត់ទោសមនុស្សយើងសព្វថ្ងៃនេះ ពុំដូចគ្នានោះ ព្រោះសាងមកខុសគ្នាហើយតាមគតិធម៌ តែខាងគតិលោកៗយោគជាដូចម្ដេចវិញដូចមនុស្សខ្លៅល្ងង់នោះ តើកើតឡើងដោយហេតុអ្វីមនុស្សឥតមិត្រសំឡាញ់នោះ តើកើតឡើងដោយហេតុអ្វី មនុស្សឥតក្ដីសុខនោះ តើកើតឡើងដោយហេតុអ្វី សូមលោកគ្រូម្ចាស់..



អធិប្បាយឲ្យទានតាមគតិលោកពិតៗ? ។

(គ) ឆ្លើយថា ឱរឿងនោះបើនឹងនិយាយដោយគតិលោក ក៏ឃើញថាមនុស្សយើងល្ងង់ខ្លៅនោះ មិនពីព្រោះហេតុអ្វី ព្រោះតែសេចក្ដីខ្ជិលប៉ុណ្ណោះឯង ដូចបទក្នុងគម្ពីរលោកនីតិថា៖

**អលសស្ស កុតោសិប្បំ អសិប្បស្ស កុតោធនំ**
**អធនស្សកុតោមិត្តំ អមិត្តស្សកុតោ បុញ្ញំ អបុញ្ញស្ស**
**កុតោ សគ្គំ។**

ប្រែថា សិល្បសាស្ត្រចំណេះវិជ្ជាមានមកអំពីទីណាដូចម្ដេចបានដល់អ្នកខ្ជិល សេចក្ដីខ្ជិលនោះមាននៅហើយ វិជ្ជាទាំងពួងក៏ពុំអាចមានដល់មនុស្សឡើយ បើចំណេះវិជ្ជាមិនមានហើយ ទ្រព្យសម្បត្តិនឹងកើតមានមកអំពីទីណាដូចម្ដេចបាន កាលបើទ្រព្យសម្បត្តិមិនមានហើយ ធ្វើម្ដេចឡើយនឹងមានមិត្រសំឡាញ់គេរាប់អាន គឺថាពុំមានបុគ្គលឯណា១ នឹងចូលមកជាមិត្រជាភក្ដិជាពួកឡើយ កាលបើមិនមានមិត្រភក្ដិហើយ សេចក្ដីសុខសប្បាយឯណាក៏មាន នឹងមានតែសេចក្ដីទុក្ខលំបាកជាប្រក្រតី កាលបើមានតែក្ដីលំបាកទុក្ខហើយ ចិត្តគិតកសាងមគ្គផលកុសលសីលទាននិងគេឯណាមាន កាលបើពុំមានកុសលបុណ្យទានហើយ ធ្វើម្ដេច

ឡើយនឹងបានសម្បត្តិសួគ៌និព្វាននិងគេ ហេតុដូច្នេះ បានជាថា សេចក្តីខ្ជិលនេះ ជានីវរណធម៌ហាមមិនឲ្យបានប្រយោជន៍ក្នុងលោកនេះ និងលោកខាងមុខ ឯងចូលចិត្តចុះ ។

(ស) ករុណា ខ្ញុំព្រះករុណាចូលចិត្តហើយ ប៉ុន្តែដែលព្រះករុណាម្ចាស់ថាចំណេះវិជ្ជានោះ គឺសិល្បវិជ្ជាដែលជាវិសេសលើសវិជ្ជា ទាំងពួងក្នុងលោកនេះ?

(គ) អើ រឿងសព្វវិជ្ជានោះ គឺវិជ្ជាអក្សរនេះឯងវិជ្ជាវិសេសលើសវិជ្ជា ទាំងអស់ក្នុងលោកតែប្រជុំចុះក្នុងវិជ្ជាអក្សរចំណែក១ ទាំងអស់ ព្រោះវិជ្ជាអក្សរនេះ ជាវិជ្ជាដំបូងជាងវិជ្ជាទាំងពួង ប្រៀបដូចកែវសំរាប់ឆ្លុះមើលវត្ថុទាំងពួង បើវិជ្ជាអក្សរនេះកើតវិបត្តិវិបល្លាសទៅកាលណាហើយ វិជ្ជាទាំងពួងក៏ពុំអាចតាំងនៅបាន ព្រោះពុំមានទីចំណាំទៅបាន ហេតុនោះទើបថាវិជ្ជាអក្សរនេះវិសេសលើសជាងវិជ្ជា ទាំងពួង ។

១ទៀត អ្នកពុំចេះអក្សរនោះ ប្រៀបដូចជាបុគ្គលមានចក្ខុងងឹត នឹងមើលនូវរូបារម្មណ៍ទាំងពួងមិនឃើញ អ្នកដែលចេះអក្សរនោះ ប្រៀបដូចបុគ្គលមានចក្ខុបរិបូណ៌ នឹងចង់មើលអ្វីក៏អាចមើលបានទូទៅ ។



(ស) ករុណាដែលលោកគ្រូម្ចាស់អធិប្បាយអ្នកពុំចេះអក្សរប្រៀបដូចជាមនុស្សខ្វាក់ អ្នកដែលចេះអក្សរថាដូចជាបុគ្គលបរិបូណ៌ដោយចក្ខុប្បសាទ បទពីរយ៉ាងនេះ ខ្ញុំព្រះករុណាស្តាប់បាន តែពុំសូវយល់សេចក្តីសព្វគ្រប់ សូមនិមន្តលោកគ្រូម្ចាស់អធិប្បាយឲ្យពិស្តារទៀត?

(គ) ឱឯងនៅសង្ស័យអ្វីទៀត បើដូច្នេះយើងនឹងសួរឯងវិញថាមានហិបឬកញ្ជើ១ ដែលគេដាក់គ្រឿងមាសគ្រឿងប្រាក់គ្រឿងស្ពាន់ លាយចូលគ្នាហើយឲ្យមនុស្សខ្វាក់មើល តើមនុស្សខ្វាក់នោះអាចយល់ស្គាល់របស់ទាំងអស់នោះបានឬទេ អាចដឹងថាវត្ថុនេះជាមាស វត្ថុនោះជាប្រាក់ជាស្ពាន់ឬទេ?

(ស) ករុណាធម្មជាតិមនុស្សខ្វាក់នោះ ពុំអាចនឹងមើលយល់ស្គាល់បានឡើយ មនុស្សដែលមានចក្ខុប្បសាទបរិបូណ៌ទើបអាចមើលយល់ស្គាល់បាន ។

(គ) អើ ដូចគ្នាមនុស្សខ្វាក់មើលវត្ថុពុំយល់ស្គាល់ជាមាសជាប្រាក់នោះលោកប្រៀបដូចជាមនុស្សពុំចេះអក្សរ អ្នកពុំចេះទុកស្មើនឹងមនុស្សខ្វាក់ អ្នកចេះអក្សរទុកស្មើនឹងមនុស្សបរិបូណ៌ដោយចក្ខុប្បសាទ ។

១ ទៀតវិជ្ជាអក្សរនេះទុកស្មើភ្នែកទិព្វមាត់ទិព្វក៏បាន ដូចយ៉ាង
សព្វតម្រាទាំងពួងមានតម្រាភូមិសាស្ត្រតម្រាពង្សាវតារជាដើម
ជារបស់បុរាណកន្លងទៅយូរហើយ យើងចេះអក្សរបានអាន
មើលក៏អាចដឹងរឿងរ៉ាវបាន និយាយប្រាប់គ្នាគ្នីបានយ៉ាងនេះទុក
ស្មើយើងមានភ្នែកទិព្វ ។

១ទៀត យើងនៅស្រុកនេះនឹងនិយាយឬប្រាប់កិច្ចការ ឬចង់
ដឹងការអ្វីៗ អំពីបែបអ្នកស្រុកឯនោះក្តី ប្រើតែអក្សរទៅគេ
ក៏បានដឹងច្បាស់ វិជ្ជាអក្សរនេះអាចចារឹតពាក្យសំដីបានសព្វ
ប្រការតម្កល់ទុកនៅអស់កាលជាអង្វែង ។

១ទៀត បើបានចេះខាងអក្សរលោកអ្នកប្រទេសក្រៅ
មានអក្សរសៀម ឬអក្សរបារាំងសែសជាដើមផង ក៏រឹតតែ
កើតចំណេះជាភិយ្យោភាព អាចដឹងវិធីក្នុងប្រទេសនោះៗបាន
ទូទៅ ដូចអ្នកមានកូនសោអាចចាក់សោបើកហិប មើលរបស់
ក្នុងហិបនោះបានដោយងាយៗ កើតបញ្ញាក្លាហានព្រោះបានដឹង
ក្បួនខ្នាតបែបផែនក្រៅស្រុកក្នុងស្រុកមិនសង្ស័យ ហេតុនោះ
ទើបយើងពោលថា សព្វវិជ្ជាទាំងពួងក្នុងលោកនេះ សឹងមានទី
រៀនចប់ទៅបាន តែវិជ្ជាអក្សរ១នេះជាវិជ្ជារៀនពុំចេះចប់



ព្រោះជាវិជ្ជាវិសេសលើសវិជ្ជាទាំងពួងក្នុងលោកនេះ គួរឯង
ចូលចិត្តចុះ ។

(ស) ករុណា ខ្ញុំករុណាស្តាប់បានចូលចិត្តហើយ ចុះវិជ្ជាអ្វីទៀ
តដែលជាវិជ្ជាបន្ទាប់រងវិជ្ជាអក្សរនេះទៅ?

(គ) វិជ្ជាលេខ ជាវិជ្ជាបន្ទាប់រងពីវិជ្ជាអក្សរនេះ លេខនិង
អក្សរជាវិជ្ជារួមនៅជាមួយគ្នា ។

(ស) សូមទាន ចុះវិជ្ជាទាំងអស់ក្នុងលោកនេះបុគ្គលឯណា
រៀនចេះចាំបានហើយ សឹងនាំមកនូវប្រយោជន៍ដល់បុគ្គលនោះ
ៗបានទទួលសេចក្តីចំរើនដូចម្តេច ឬមានវិជ្ជាឯណា១ ជាសឹក
សត្រូវដល់បុគ្គលអ្នកចេះនោះខ្លះដែរ?

(គ) ថា វិជ្ជាក្នុងលោកចាត់ជាពីរប្រការ គឺទុវិជ្ជាប្រការ១
សុវិជ្ជាប្រការ១ វិជ្ជាណាដែលបុគ្គលចេះដឹងហើយ សំដែងឡើង
ធ្វើឡើងអាចនឹងនាំមកនូវសេចក្តីទុក្ខ សេចក្តីវិនាសផល
ប្រយោជន៍ដល់បុគ្គលដទៃផង ដល់អាត្មាឯងផងយ៉ាងនោះហៅ
ថា ទុវិជ្ជាពិតមែន វិជ្ជាឯណាដែលបុគ្គលសំដែងឡើង ធ្វើឡើង
ហើយអាចនឹងនាំមកនូវសេចក្តីសុខ សេចក្តីចំរើនដល់បុគ្គលដ
ទៃផង ដល់អាត្មាផង យ៉ាងនេះវិជ្ជានោះឈ្មោះសុវិជ្ជាបុគ្គលឯណា

ទ្រទ្រង់នូវចំណែកសុវិជ្ជាបុគ្គលនោះទទួលសេចក្ដីសុខសេចក្ដីចំរើនសួស្ដីមង្គល បុគ្គលនោះឯណាទ្រទ្រង់ចំណែកទុវិជ្ជា បុគ្គលនោះទទួលសេចក្ដីទុក្ខទោស សេចក្ដីវិនាស សុវិជ្ជាជាគុណដល់អ្នកចេះដឹង ទុវិជ្ជាជាទោសដល់អ្នកដែលទ្រទ្រង់នោះ ៗ

(ស) សូមទានអត់ទោសចុះ បុគ្គលខ្លះមានវិជ្ជាចំណេះខ្ពស់ហើយ តែធ្លាកខ្លួនចុះចាកវិជ្ជានោះវិញទទួលតែសេចក្ដីទុក្ខទោសគរហានិន្ទាវិជ្ជាដែលចេះដឹងហើយប្រើវិញពុំបាន យ៉ាងនេះគឺហេតុអកុសលអ្វី?ៗ

(គ) ថាអ្នកនោះមានវិជ្ជាខ្ពង់ខ្ពស់ល្អហើយ តែធ្វើឲ្យវិជ្ជាប្រើពុំបានវិញនោះព្រោះឥតមារយាទ ឥតក្ដីហិរិឱត្តប្បៈ គ្មានខ្មាសបាប ខ្លាចបាប ប្រព្រឹត្តខ្លួនទៅតាមគតិមនុស្សពាលផ្សេងៗ យ៉ាងបុគ្គលនោះឯងទើបត្រូវទទួលក្ដីទុក្ខទោស គរហានិន្ទាគ្រប់ប្រការក្នុងលោកនេះ ៗ

(ស) ចុះមនុស្សយើងធ្វើខ្លួនឲ្យបរិសុទ្ធនោះតើត្រូវប្រព្រឹត្តយ៉ាងណា?

(គ) ថាឯការដែលនឹងធ្វើនូវខ្លួនឲ្យបរិសុទ្ធនោះតោងឲ្យចំរើននូវសេចក្ដីសុខដល់អ្នកដទៃ ទើបខ្លួនបានទទួលសេចក្ដី



បរិសុទ្ធនោះ បើឲ្យក្ដីទុក្ខគេហើយ, ក្ដីទុក្ខនោះឯងនឹងមានដល់ខ្លួនវិញមិនខាន ខ្លួនឯងនឹងទទួលក្ដីបរិសុទ្ធឯណាបាន ៗ

(ស) មនុស្សយើងដែលលោកសន្មតហៅថាមនុស្សល្អនោះ តើមានអាការកិរិយាយ៉ាងណា ដែលហៅថាមនុស្សអាក្រក់នោះ តើមានអាការកិរិយាយ៉ាងណា?

(គ) ថាមនុស្សដែលល្អនោះ គឺមនុស្សណាប្រកបដោយក្ដីសុចរិត៣ ប្រការគឺ កាយសុចរិត១ វចីសុចរិត១ មនោសុចរិត១ ប្រព្រឹត្តខ្លួនជាបុគ្គលប្រដៅងាយ មានហិរិ ឱត្តប្បៈជាជញ្ជាំង ឬកំផែងបិតបាំងកាយ មិនឲ្យក្ដីអកុសលធម៌ចូលញាំញីខ្លួនបាន យ៉ាងនេះ មនុស្សនោះឯងហៅថាមនុស្សល្អបាន ៗ មនុស្សប្រកបដោយក្ដីទុច្ចរិត៣ ប្រការគឺកាយទុច្ចរិត១ វចីទុច្ចរិត១ មនោទុច្ចរិត១ ប្រព្រឹត្តខ្លួនជាបុគ្គលប្រដៅក្រ ពុំមានហិរិឱត្តប្បៈធម៌បិទបាំងកាយ ហើយផ្សាយចិត្តក្នុងការអកុសលផ្សេងៗ វង្វេងដោយគតិពាលពិតមនុស្សយ៉ាងនេះឯង ហៅថាមនុស្សអាក្រក់ក្នុងលោកយើងនេះ ៗ

(ស) សូមទានមេត្តាប្រោស ពាក្យសុភាសិតប្រដៅថាឲ្យវៀរក្ដីរកស៊ីក្នុងការមិច្ឆាជីវៈ ឲ្យរកស៊ីតាមផ្លូវសម្មាជីវៈ ផ្លូវ...

មិច្ឆាជីវៈនោះដូចម្តេច ផ្លូវសម្មាជីវៈនោះដូចម្តេច?

(គ) ឱ ផ្លូវមិច្ឆាជីវៈនោះគឺប្រកបការរកស៊ីខុសគន្លងធម៌ មានលក់គ្រឿងសស្ត្រាប្រហារជីវិតសត្វជាដើម មានលក់ដូរថ្នាំបំពុលជាបរិយោសាន ព្រមទាំងប្រព្រឹត្តធ្វើជាបន្ទាល់កោង ទាំងឆក់កុហកគេដោយឧបាយ ដោយគំនិតកោងផ្សេងៗ ការរកស៊ីខុសគន្លងធម៌នោះ ហៅថាមិច្ឆាជីវៈគឺចិញ្ចឹមជីវិតខុសនឹងទទួលទុក្ខទោមនស្សផ្សេងៗ ឯការរកស៊ីផ្លូវសម្មាជីវៈនោះ គឺវៀរបង់ផ្លូវមិច្ឆាជីវៈនេះឯង ហៅថាចិញ្ចឹមជីវិតដោយធម៌ ឈ្មោះថាសម្មាជីវៈ ១ទៀតត្រូវវៀរផ្លូវ ដែលមហាក្សត្រទ្រង់ហាម ដូចយ៉ាងគយដារដែលរាជការតាំង ហើយទៅប្រព្រឹត្តកន្លងព្រះរាជអាជ្ញា យ៉ាងនេះប្រការ១ ត្រូវវៀរផ្លូវល្បែងផ្សេងៗមានល្បែងជល់មាន់ ជល់ត្រីជាដើម នេះប្រការ១ ត្រូវវៀរល្បែងស្រីល្បែងស្រា វៀរសេពគប់ភឿនពាលនាំលេងយប់ ស្វែងមើលល្បែងផ្សេងៗមានល្បែងច្រៀងរាំជាដើមយ៉ាងនេះប្រការ១ៗ

(ស) សូមទាន ការត្រាច់យប់នោះមានទោសយ៉ាងណាខ្លះ?

(គ) ឱ ការដែលដើរលែងយប់នោះ មានទោស៥ប្រការគឺ៖

១- ដើរទៅហើយខាតផ្លូវរវាំងរក្សាផ្ទះ ទីលំនៅខ្លួនជូន



ប្រពន្ធកូន ឬបងប្អូនកើតហេតុដោយរោគាព្យាធិ ឬដោយហេតុឯណា១ ក្តីចំណែកខ្លួនមិនដឹងក៏ខូចប្រយោជន៍ជាទោស១ៗ

២- ជួនកាលដើរទៅហើយ ពើបប្រទះលើសត្វមានពិសវាចិកខាំ បាននូវទុក្ខវេទនា យ៉ាននេះជាទោស១ៗ

៣- ជួនដើរទៅជាន់ដើងចោរ ដែលគេដេញចោរមក រាចោរនោះវាវេះបាត់ទៅ គេឃើញឯងគេក៏ចាប់ថាជាចោរ យ៉ាងនេះជាទោស១ៗ

៤- ជួនដើរទៅហើយប្រទះនឹងចោរ ឬអ្នកដែលមានពៀរវេរាដល់អ្នកឯណា១ គេឃើញឯងក៏សំគាល់ជាចោរ ឬថាអ្នកដែលមានពៀរនោះ គេបាញ់ចាក់សំឡាប់ទៅ យ៉ាងនេះជាទោស១ៗ

៥- អ្នកដើរយប់ ជាទីនាំឲ្យគេគរហានិន្ទាបាន គឺថាបើគេបាត់របស់ទ្រព្យអ្វីឯណា១ គេដិតចិត្តសង្ស័យខ្នែងឯង ព្រោះឃើញថាឯងដើរលេងយប់យ៉ាងនេះជាទោស១ៗ

(ស) សូមទាន ការដែលកើតមកជាមនុស្សត្រូវចែងកាលប៉ុន្មានកាល?

(គ) ត្រូវចែងកាលតាមវ័យទាំង៣ ប្រការហៅថាបឋមវ័យ

ប្រការ១ ហៅថាមជ្ឈិមវ័យ ប្រការ១ ហៅថាបច្ឆិមវ័យ ប្រការ១ក្នុងបឋមវ័យនោះត្រូវតែស្វែងរករៀនវិជ្ជាសិល្បសាស្ត្រនឹងចំណេះដឹងទាំងទួង លុះដល់មជ្ឈិមវ័យគឺវេលាដែលតាំងនៅក្នុងកាលខ្លួនមានបុត្រភរិយា ហើយត្រូវប្រកបការផ្លូវរកស៊ីមានផ្លូវជួញ ផ្លូវធ្វើស្រែចំការជាដើម សន្សំទ្រព្យសម្បត្តិឲ្យកើតមាន លុះដល់បច្ឆិមវ័យខាងចុង គឺខ្លួនចាស់ជរាហើយត្រូវតែស្វែងរកផ្លូវកុសល គឺបរិច្ចាគទាន រក្សាសីលចំរើនភាវនា ជាបច្ច័យរបស់ខ្លួនទៅបរលោក។

(ស) មាតាបិតាមានគុណូបការដល់បុត្រ បុត្រគួរសង្គ្រោះដោយផ្លូវប៉ុន្មានប្រការ?

(គ) បុត្រត្រូវសង្គ្រោះមាតាបិតាដែលជាបុព្វការីនោះ ដោយបទសង្គ្រោះ៥ ប្រការគឺៈ

១- ករណាំ គិតថាអាត្មាអញនេះ គឺមាតាបិតាលោកចិញ្ចឹមមកយូរហើយ គួរតែចិញ្ចឹមលោកវិញ។

២- កិច្ចករណាំ ការងារនៃមាតាបិតាមានឡើង ត្រូវបញ្ឈប់ការងាររបស់ខ្លួនសិន ទៅជួយធ្វើកិច្ចការមាតាបិតានោះ ត្រូវតែបានសម្រេច។



៣- កុលវង្សថបនំ កូនត្រូវប្រព្រឹត្តរក្សាវង្ស តម្កល់វង្សនៃត្រកូលឲ្យឋិតថេរនៅ ការកេរ្តិ៍មាតាបិតាកុំឲ្យសាបសូន្យវិនាសទៅបាន។

៤- ទាយជ្ជារហិបដិបនំ កូនត្រូវបំរើមាតាបិតាដោយសុចរិតតាំងចិត្តសំឱតគោរពកោតខ្លាច អាចទទួលនូវទ្រព្យមតករបស់មាតាបិតា។

៥- ទក្ខិណានុប្បទានំ បើមាតាបិតាដល់នូវបរណភាពហើយ កូនត្រូវទទួលតបគុណដោយធ្វើឈាបនកិច្ចធ្វើបុណ្យ សាងកុសលបញ្ជូនផលទក្ខិណានុប្បទាន ទៅមាតាបិតាដែលលោកចែកស្ថានទៅបរលោកនោះ។

(ស) ប្តីសង្គ្រោះប្រពន្ធមានប៉ុន្មានប្រការ ប្រពន្ធសង្គ្រោះប្តីតើមានប៉ុន្មានប្រការ?

(គ) ប្តីសង្គ្រោះប្រពន្ធនោះមាន៥ ប្រការគឺៈ

១- សមាននាយ ប្រដៅសព្វសារពើពោលពាក្យពិរោះសរសើរដោយលក្ខណៈប្រព្រឹត្តជាប្រយោជន៍ ពោលពាក្យជាបិយវចនៈ។

២- អវិមាននាយ ពុំបានមើលងាយជេរវាយដូចទាសីទាសា

កម្មករឡើយ ។

៣- អនតិចរិយាយ ពុំប្រព្រឹត្តបែកចិត្តពីភរិយា មិនកន្លងចិត្តភរិយា គឺមិនមានស្ត្រីដទៃទៀតជាភរិយាឡើយ ។

៤- ឥស្សរិយវោស្សគ្គេន ប្រគល់នូវរបស់ទាំងពួង មានផ្ទះបាយជាដើមឲ្យដល់ភរិយា ។

៥- សង្គានុប្បទានេន ឲ្យនូវគ្រឿងប្រដាប់មានសំពត់អាវជាដើម ឲ្យភរិយាដោយសមគួរតាមបវេណី ។

ប្រពន្ធសង្គ្រោះប្ដីមាន៥ ប្រការគឺ៖

១- សុសំវិហិតកម្មន្តា ចាត់ចែងការងារដោយប្រពៃ និងតាក់តែងភោជនាហារ មិនឲ្យហួសពេលវេលា ។

២- សង្គហិតបរិជនា ប្រពន្ធត្រូវសង្គ្រោះដល់ជនក្នុងផ្ទះ និងញាត់ខាងប្ដីរាប់អានឲ្យដូចញាតិរបស់ខ្លួន ។

៣- អនតិចារិនី មិនប្រព្រឹត្តកន្លងចិត្តប្ដី គឺមិនមានបុរសដទៃជាប្ដីឡើយ ។

៤- សមតញ្ច អនុរក្ខតិ រក្សាទ្រព្យសម្បត្តិដែលប្ដីរកបានមកមិនឲ្យអន្តរាយ ដោយការមិនគួរ ។

៥- ទក្ខា ច ហោតិ អនលសា ឈ្លាសក្នុងការស្ត្រីឬមិនខ្ជិលច្រអូស ។



មាតាបិតាអនុគ្រោះបុត្រដោយបទ៥ ប្រការគឺ៖

១- ចាចា និវាមន្តិ ហាមកូនចាកផ្លូវបាបគឺកុំឲ្យធ្វើបាបកម្ម ។

២- កល្យាណេ និវេសេន្តិ ញ៉ាំងកូនឲ្យតម្កល់នៅក្នុងការកុសល ។

៣- សិប្បំ សិក្ខាបេន្តិ ញ៉ាំងកូនឲ្យសិក្សារៀនសូត្រសិល្បសាស្ត្រផ្សេងៗ ។

៤- បដិរូបេន ទារេន សំយោជេន្តិ លុះកូនធំឡើងត្រូវប្រកបការរកភរិយាដែលមានរូបមានសម្បត្តិសមគួរផ្សំឲ្យកូន គឺរៀបអាពាហ៍ពិពាហ៍ឲ្យកូន ។

៥- ទាយជ្ជំ និយ្យាទេន្តិ ប្រគល់ទ្រព្យមតកឲ្យក្នុងសម័យដ៏សមគួរ គឺឲ្យក្នុងនិច្ចសម័យក្នុងកាលសម័យ១ ។

(ស) បុគ្គលដែលគួរយើងនឹងបូជាគោរពក្នុងលោកនេះមានប៉ុន្មានយ៉ាង?

(គ) បុគ្គលដែលគួរនឹងបូជានោះ ចែកដោយឧក្រិដ្ឋមាន៣យ៉ាងគឺ ព្រះសម្មាសម្ពុទ្ធ១ ព្រះបច្ចេកពុទ្ធ១ ព្រះអរិយសាវក១ ចែកដោយសាមញ្ញទៀត គឺចំណែកខាងបព្វជិតនោះ មានគ្រូឧបជ្ឈាយាចារ្យជាទីគោរពបូជារបស់កូនសិស្ស១ ភិក្ខុមាន

វិស្សាចាស់ ជាទីគោរពបូជារបស់ភិក្ខុទី១ ប៉ែកខាងឃរាវាស នោះ គឺបងប្រុសបងស្រីជាទីគោរពបូជា របស់ប្អូនៗ១ មាតាបិតាជាទីគោរពបូជារបស់កូនប្រុសកូនស្រី១ ស្វាមីអពុកក្មេកម្តាក្មេកជាទី គោរពបូជារបស់ភរិយាកូនប្រសា១។

(ស) កើតមកជាមនុស្សក្នុងលោកនេះ ត្រូវធ្វើពលិកម្មប៉ុន្មានយ៉ាង?។

(គ) ឱពលិកម្មនោះមាន៥ យ៉ាងអ្នកឯងស្តាប់ចុះ។

១ ញាតិពលិ អធិប្បាយថា បុគ្គលជាញាតិសាលោហិតរបស់ខ្លួនពិតៗ ខ្លួនគួររាប់អានជួយទំនុកបំរុង ដោយឲ្យនូវវត្ថុផ្សេងៗ មានបាយទឹកប្រាក់មាសជាដើម។

២ អតិថិពលិ អធិប្បាយថាបុគ្គលជាភ្ញៀវទើបដល់មកកាន់ទីលំនៅខ្លួនៗ គួរធ្វើបដិសណ្ឋារសួរទទួលរាប់អានតាមសម័យ គឺឲ្យនូវបច្ច័យមានភោជនាហារជាដើម។

៣ បុព្វបេតពលិ អធិប្បាយថា ញាតិមិត្រឯណារស់នៅក្តី មរណៈកាលទៅកាន់បរលោកហើយក្តី គួរធ្វើការកុសលឯណា១ ឧទ្ទិសផលជូនទៅដល់ញាតិនោះ។

៤ រាជពលិ អធិប្បាយថា រាជការរបស់មហាក្សត្រមានទៀងគួរខ្លួនទទួលរាជការ ឆ្លងព្រះតេជព្រះគុណឬ ទទួលបង់ថ្លៃរាជការ។



៥ ទេវតាពលិ អធិប្បាយថា ពួកទេវតាទាំងឡាយបណ្តាដែលមានសក្តានុភាពបានជួយសង្គ្រោះដោះទុក្ខខ្លួន គួរធ្វើសក្ការបូជាដល់ទេវតាទាំងឡាយនោះ។

ឯពលិការនោះ គួរយើងបូជាដល់បុគ្គល៥ ជំពូកដូចសេចក្តីដែលបានអធិប្បាយមកនេះ។

(ស) ស្ត្រីយ៉ាងណា ហៅថាល្អលើសស្ត្រីទាំងពួងក្នុងលោកនេះ ទឹកយ៉ាងណា ជាទឹកផ្អែមឆ្ងាញ់លើសទឹកទាំងពួងក្នុងលោកនេះ ត្រីយ៉ាងណា ដែលមានរសជាតិឆ្ងាញ់ពីសាលើសត្រីទាំងពួងក្នុងលោកនេះ?។

(គ) ឱ ឯជាតិស្ត្រីល្អលើសគេនោះ បើតាមនិយាយដោយរូប គឺស្រីដែលប្រកបដោយបញ្ចពិធកល្យាណី មានលំអសក់ជាដើម តែបើនិយាយដោយធម៌ គឺស្ត្រីដែលមានសីលមារយាទល្អនោះឯង បើនិយាយដោយទោហារវិញនោះ គឺស្ត្រីប្រពន្ធគេនោះឯង ហៅថាល្អលើសលែងស្ត្រីក្នុងលោកហេតុបានជាថាលើសគេនោះ ព្រោះស្ត្រីប្រពន្ធគេនោះមានទោសខុសទាំងពីរផ្លូវថា

បើបុរសណាទៅប្រព្រឹត្តកន្លងបទវេណីនោះហើយ គឺក្នុងលោក
នេះតែគេដឹងឮហើយ គេក៏ចាប់ទៅប្ដឹងដល់សាលាជំនុំៗ លោក
ក៏ពិនិច្ឆ័យលក់ឬដាក់គុកធ្វើទោសទៅផ្សេងៗឯខាងផ្លូវបរ
លោកនោះសោត ក៏បានបាបគឺធ្លាក់ទៅសោយទុក្ខវេទនាក្នុងអ
បាយភូមិទាំង៤ មាននរកជាដើម ការដែលដឹងថាមានទោស
យ៉ាងនេះហើយ ហេតុអ្វីបុរសលែងពុំបាន បើដូច្នោះស្ត្រីនោះ
មិនល្អលើសគេហើយហះ បានជាបុរសលែងពុំបាន យ៉ាននេះឯង
ហៅថាស្ត្រីល្អលើសលែងក្នុងលោក ។

២ ឯទឹកដែលផ្អែមពិសា លើសទឹកទាំងពួងនោះគឺសុរានេះ
ឯងមែនពិតឯទឹកសុរាបានជាថាផ្អែមលើសលែងនោះ ព្រោះ
ទឹកសុរានោះមានអំណាចអាចហាមមិនឲ្យបិទ មិនឲ្យធ្វើខ្លួនឯង
តោងចេញប្រាក់ទៅទិញចិន ឯទោសផឹកសុរាគឺបង់ប្រាក់១
គឺផឹកទៅហើយកើតស្រវឹងវង្វេងចិត្ត ទៅប្រព្រឹត្តការជួអាក្រក់
ផ្សេងៗ មានបង្កពាក្យជម្លោះប្រកែកប្រកួតជាដើម១ មាន
ទោសធ្លាក់ទៅអបាយភូមិទាំង៤ មាននរកជាដើម១ អ្នកលេង
សុរា សឹងដឹងប្រាកដថា ផឹកសុរានោះជាទីនាំមកនៅសេចក្ដីទុក្ខ
ទោសទាំងអស់ តែនឹងលះលែងពុំបានបើដូច្នោះ សុរានោះមិន



ជាផ្អែមលើសគេហើយហះ បានជាមនុស្សយើងលះលែងពុំរួច
យ៉ាងនេះ ។

៣ ឯត្រីដែលមានរសពិសាលើសត្រីនានានោះគឺត្រីព្រលូង
នោះឯង បានថាជាត្រីព្រលូងមានរសពិសានោះ ព្រោះដឹងថា
ត្រីព្រលូងនេះចួនបរិភោគទៅហើយពុលក៏មាន តែនឹងលះបង់
ពុំបានបើដូច្នោះ ត្រីព្រលូងនោះមិនឆ្ងាញ់លើសគេហើយហះ
បានជាមនុស្សយើងលះលែងពុំបាន ។

(ស) ករុណាចូលចិត្តហើយ ១ទៀតការទទួលទានសុរានោះ
ហេតុអ្វីថាមានបាប សុរានោះទទួលទានទៅជាថ្នាំកែរោគក៏
មានជាគុណឲ្យទទួលទានបាយបានក៏មាន សូមនិមន្តលោកគ្រូកែ
ខែឲ្យចូលចិត្តបន្តិចមើល? ។

(គ) តបថា ការផឹកសុរានោះបានជាបាបព្រោះព្រះបរម
គ្រូទ្រង់ហាម ពុំឲ្យសេពសុរានោះព្រោះជារបស់នាំឲ្យស្រវឹង
នាំឲ្យខូចចិត្ត ត្បិតមនុស្សយើងសព្វថ្ងៃនេះ មានស្រវឹងនៅពេ
ញខ្លួនហើយសេចក្ដីស្រវឹងនេះ លោភា គឺសេចក្ដីជាប់ជំពាក់
ឬចំណង់ចង់បាន នេះជាស្រវឹងប្រការ១ ទោសោ គឺសេចក្ដីក្រោ
ធខឹងនេះស្រវឹងប្រការ១ មោហោ គឺសេចក្ដីល្ងង់វង្វេងពុំស្គាល់

ខុសត្រូវ នេះស្រវឹងប្រការ១ មានះទិដ្ឋិ គឺសេចក្ដីរឹងត្អឹងកាន់ខ្លួន
អួតខ្លួន នេះជាស្រវឹងប្រការ១ ស្រវឹងទាំងអស់នេះតែងមាន
នៅសំរាប់រូបមកហើយៗមកថែមផឹកទឹកស្រវឹងចូលទៅទៀត
ស្រវឹងក៏នាំស្រវឹងចាស់ឲ្យមានកម្លាំងក្លាហានឡើងគឺខ្លួនអ្នកលោ
ភក៏នាំឲ្យលោភខ្លាំងឡើងខ្លួនអ្នកទោសៈ ឬមោហៈ មានៈទិដ្ឋិ
ក៏នាំឲ្យចំរើន ទោសៈ មោហៈ មានៈទិដ្ឋិខ្លាំងក្លាឡើង មួយទៀត
ពាក្យជាអាថ៌កំបាំង ឬកេរ្ដិ៍ខ្មាសជារបស់មិនគួរនាំចេញសំដែង
ប្រាប់គេ នោះក៏អាចនាំចេញបង្ហាញគេបានទាំងអស់ ១ទៀត
នាំឲ្យកើតជំលោះប្រកែក ចួនក៏ត្រូវព្រះរាជអាជ្ញា បង់ទ្រព្យ
ធនទៅផ្សេងៗ មួយទៀតទោសសុរានេះនាំឲ្យកើតរោគ
ឆាប់ងងឹតភ្នែក ឆាប់ជរាគ្រាំគ្រាទ្រោមត្រុឌទោសយ៉ាងនេះ
ឯង បានថាមានបាបក្នុងលោកនេះ ១ទៀត ប្រាក់ដែលទៅទិញ
សុរានេះក្នុងមួយឆ្នាំៗ បើជាប្រមូលទុកគង់បាននៅច្រើន គ្រាន់
ទុករក្សាការពារអន្តរាយក្នុងគ្រាក្រ ទុកទិញបាយត្រីចំណើង
ទៀតចែកកូនប្រពន្ធអាស្រ័យជាជាង ឬឯងយល់ដូចម្ដេច។

(ស) ករុណា ខ្ញុំករុណាចូលចិត្តហើយ អើយ៉ាងជក់អាភៀនជក់
កញ្ឆានោះ តើមានទោសយ៉ាងណាខ្លះទាន?។



(គ) ឱ រៀងជក់អាភៀនជកកញ្ឆានោះ មានទោសប្រហែ
លៗនឹងសុរានោះដែរ ឯងគិតមើលចុះសុរាអាភៀននោះ សឹង
មានផាសុីគេទិញដាច់មុខក្នុងស្រុកមួយៗ ធ្វើលក់បានតែម្នាក់ៗ
ម៉្លោះហើយគេចង់ដំឡើងថ្លៃយ៉ាងណា ក៏តាមតែចិត្តគេទាំងអស់
តម្លៃនោះលើសប្រមាណឃើញចុះទុនយ៉ាងច្រើនៗ បើខ្លួនទៅ
ប្រកបគិតធ្វើឡើងបាន តែនាយផាសុីគេដឹងហើយគេក៏ចាប់
លក់ទ្ពុតាមច្បាប់ ប្រះរាជបញ្ញត្តិ ត្រូវបង់ប្រាក់ ធ្លាក់ដល់ទោស
ជាប់គុកជាប់ក្ដីក្នុងលោកនេះ ១ទៀតអ្នកជក់អាភៀននោះសព្វ
ថ្ងៃនេះ ឯងយល់ស្រាប់ហើយ អ្នកណាមានរូបល្អខ្លះ អ្នកល្អណាគេ
គាប់ចិត្តខ្លះ សេចក្ដីចំរើនមានយ៉ាងណាខ្លះគួរឯងគិតមើលចុះ ឯ
រឿងកញ្ឆាទៀត ក៏ប្រហែលៗនឹងអាភៀនដែរ សឹងជារបស់
នាំឲ្យកាយវិកលវិការនាំឲ្យឆ្កួតចិត្តប្រព្រឹត្តទៅក្នុងកិរិយាទាប
ថយទាំងអស់។

(ស) ករុណា ខ្ញុំយល់ហើយទានមួយទៀតការគួរឲ្យខ្លាចក្នុង
លោកនេះតើឲ្យខ្លាចអ្នកណាទាន?។

(គ) ឱ ការដែលគួរឲ្យខ្លាចនេះ ក្នុងចិត្តគំនិតឯងតើខ្លាចអ្វី
សព្វថ្ងៃនេះ?។

(ស) ខ្ញុំព្រះករុណាសព្វថ្ងៃនេះគិតខ្លាចស្តេច១ ខ្លាចអ្នកមានសម្បត្តិ១ យ៉ាងនេះត្រូវឬមិនត្រូវ?។

(គ) ឯងគិតខ្លាចស្តេច ខ្លាចអ្នកមានសម្បត្តិនោះមិនត្រូវទេ ខ្លាចអីស្តេចនោះ បើយើងទៅប្រព្រឹត្តការឯណាឲ្យខុសនឹងព្រះរាជបញ្ញត្តិ ក្រិត្យព្រះអាជ្ញាតីយើងទៅធ្វើការខុស មានធ្វើចោរកម្មជាដើមនោះទើបមហាក្សត្រ លោកដាក់ទោសទណ្ឌកម្មយើងបាន បើយើងរក្សាខ្លួនយើងឲ្យត្រឹមត្រូវតាមច្បាប់ហើយ យើងប្រព្រឹត្តកាយប្រព្រឹត្តចិត្តសុចរិត តាមព្រះរាជប្រកាសហើយស្តេចនោះ លោកនឹងដាក់ទោសទណ្ឌកម្មយើងឯណាបាន ឯអ្នកមានទ្រព្យសម្បត្តិនោះសោត បើយើងកុំទៅរកខ្ចីទ្រព្យគេ យើងកុំទៅពឹងទ្រព្យគេៗ នឹងមកធ្វើទោសយើងឯណាបាន ហេតុនោះទើបថាយើងមិនត្រូវខ្លាច។

(ស) ចុះលោកគ្រូឲ្យខ្លាចមនុស្សយ៉ាងណាវិញ?

(គ) ត្រូវឲ្យខ្លាចមនុស្សពាលជំពូក១ ទើបត្រូវព្រោះមនុស្សពាលក្រនឹងគេចរត់អំពីវាទៅបានពាលនោះ ពុំប្រាកដថានៅត្រង់នេះត្រង់នោះបានជួនណាកូនប្រពន្ធឯង បងប្អូនឯង ត្រឡប់ជាពាលវិញក៏មាន ពាលនេះរក្សាប្រពេកណាស់ កុំថាដល់ពាល



ខាងក្រៅនោះឡើយ តែពាលខាងក្នុង នៅជាមួយនឹងខ្លួនក៏ពុំដឹងថា ជាពាលមកដល់ថ្ងៃណាខែណា ពេលណាដូចប្រពន្ធដែលរួមសុខទុក្ខផងគ្នា ជួនណាក៏ប្រែចិត្តគិតស្អប់ប្ដី ទៅស្រឡាញ់ប្រុសដទៃ ប្រើសហាយវាឲ្យប្រហារប្ដីដល់នូវសេចក្ដីស្លាប់ទៅវិញក៏មាន ឯងរឿងនិទានប្រពន្ធសម្លាប់ប្ដី រឿងបុរាណក៏មាននិយាយមកថា មានបុរសម្នាក់មានភរិយាជាទីគាប់ចិត្ត នៅរួមសុខទុក្ខនឹងគ្នាអស់កាលជាយូរមក តែបុរសនោះមានប្អូនប្រុសម្នាក់យកមកនៅរកស៊ីជាមួយផង លុះនៅយូរមក មេប្រពន្ធនោះទៅប្រតិព័ទ្ធស្រឡាញ់ចៅប្អូន ថ្ងៃមួយបានលួចលាក់ធ្វើស្ម័គ្រសង្វាសនឹងគ្នា ដល់ក្រោយមកនោះ និយាយញុះចៅប្អូនថ្លៃឲ្យសម្លាប់ប្ដី ឯចៅប្អូនថ្លៃនោះ ហេតុតែជាមនុស្សលុះក្នុងអំណាចភ្លើងរាគខ្លាំងក៏លុះពាក្យញុះញង់នោះ កើតទ្រុះមិត្រប្រទុស្តបងអាត្មា ទើបកាន់ដាវទៅចាំនៅនាកំពង់ទឹក លុះបងទៅងូតទឹកចៅប្អូននោះ ក៏ពិឃាតបងនោះដល់នូវមរណកាលកណ្ដាលផ្លូវទៅ ហើយក៏បានយកគ្នាជាប្ដីប្រពន្ធតមក។

រឿងរ៉ាវនេះ មានសេចក្ដីពិស្ដារក្នុងព្រះគម្ពីរសង្គហៈឯនោះ អញ្ជើញទៅមើលចុះ។

មានរឿងក្នុងកាលឥឡូវនេះក៏មាន ដូចរឿងស្ត្រីម្នាក់នៅ
ស្រុកចក ខេត្តត្នោត ស្ត្រីនោះជាកូននាយជាងមាសមាតាបិតា
ដាក់ទុកឲ្យមានស្វាមី លុះនៅយូរមក មេនោះមានសហាយក្បត់
កើតស្អប់ប្តីអាត្មាទើបវានិយាយបញ្ឆោតប្តីនោះ ឲ្យទៅបោច
វល្លិក្នុងព្រៃស្ងាត់ ហើយវាឲ្យសហាយនោះ ទៅតាមសម្លាប់ចៅ
ប្តីនោះចោល ៗ

១ទៀតមានមេម្នាក់ប្រពន្ធមេឃុំ នៅភូមិស្រុកស្មោងជីក្រែង
ស្ត្រីនោះឯងទៅសហាយនឹងចៅអធិការម្នាក់ កើតស្អប់ប្តីអាត្មា
ទើបវាទៅជួលអ្នកលេងឲ្យបាញ់មេឃុំជាប្តីស្លាប់ទៅ ៗ

**ចប់ប្រពន្ធពាល។**

រឿងកូនពាលវិញនោះ

គឺកូនជាអវជាតបុត្រ អកតញ្ញូពុំដឹងគុណមាតាបិតាអាចសម្លាប់
មាតាបិតា ដូចនិទានព្រះមោគ្គល្លានត្ថេរ កាលនៅក្នុងអតីតជាតិ
នៅឡើយ លោកកើតជាមាណពម្នាក់ លុះអំណាចមេភរិយាវា
ញុះឲ្យមាណពនោះ នាំមាតាបិតាទៅសម្លាប់ចោលបង់ក្នុងព្រៃ
មាណពនោះត្រូវទោសអនន្តរិយកម្ម ធ្លាក់ទៅសោយទុក្ខវេទនា
ក្នុងមហាអវិចិនរកអស់កំណត់ លុះដល់ភទ្ទកប្បនេះ គ្រាដែល



ព្រះសម្មាសម្ពុទ្ធជាម្ចាស់យើងបានត្រាស់ឡើង មាណពនេះបាន
មកកើតជាព្រះមោគ្គល្លានត្ថេរ ជាអគ្គសាវកខាងឆ្វេង ៗ

រឿងបិតុឃាត ដូចនិទានព្រះបាទអជាតសត្រូវទៅសេគ
គប់នឹងទេវទត្ត កើតមោហចិត្តគិតចង់បានរាជសម្បត្តិព្រះវររាជ
បិតា ចាប់ព្រះបាទពិម្ពិសាររាជជាព្រះវររាជបិតា ប្រហារជីវិត
ដល់នូវមរណភាពទៅ ៗ

រឿងនិទានអស់នេះ មានសេចក្តីពិស្តារក្នុងព្រះគម្ពីរមង្គល
លត្ថទីបនីឯនោះ ហេតុនោះទើបហៅថាមនុស្សពាលនោះ គួរ
ខ្លាចក្រៃពេកណាស់ព្រោះនៅជិតជាប់នឹងអាត្មាពុំដឹងជានឹងកើត
មកក្នុងថ្ងៃណា នឹងគេចរត់ឲ្យផុតចេញពីវាទៅបាន ៗ

១ទៀត ឯមនុស្សពាលនេះចេះឧបាយកលបញ្ឆោតបញ្ឆុក
ច្រើនយ៉ាងណាស់ តែពុំមានបញ្ញាត្រិះរិះគិតឲ្យដឹងកលអាការវា
ហើយក៏នឹងបង់ខ្លួនបងទ្រព្យទៅដោយអំពើពាលនោះពុំខាន
ដូចនិទានឃុនវ៉ាតឲ្យមនុស្សពាលវាធ្វើបាន ឯនិទាននោះដោយ
ឮថាមានកាលថ្ងៃ១ មានមនុស្សម្នាក់ វាយកខ្សែមាសមួយខ្សែ
ឡើងទៅលើផ្ទះឃុនវ៉ាត ហើយវានិយាយថា "ខ្ញុំបាទទ័លចាយ
ពេកណាស់ ខ្ញុំយកខ្សែនេះមកបញ្ចាំនឹងលោក សូមបញ្ចាំទុក

ប្រាក់៣០ រៀលខ្ញុំបាទជូនការលោក១ ខែ ៣កាក់ៗរៀងទៅ សូមលោកមេត្តាជួយដោះធុរៈខ្ញុំបាទម្តងនេះទៅ"ៗ ឃុនវ៉ាតថា "ខ្សែឯងនេះមាសតម្ងន់ប៉ុន្មានដំឡឹងប្រាប់មក? ថា "ខ្សែខ្ញុំបាទនេះធ្វើមកទម្ងន់៣ ដំឡឹង២ជី"ៗ ឃុនវ៉ាកថា "ខ្សែឯងនេះក្រែងក្រឡៃទេដឹង យើងនៅសង្ស័យណាស់?" បាទខ្សែខ្ញុំបាទនេះ គឺមាសសុទ្ធពិតប្រាកដមែន បើលោកមិនជឿខ្ញុំបាទសូមអញ្ជើញលោកយកទៅឲ្យជាងគេសាក ឬកាត់មើលចុះបើទៅជាក្រឡៃដូចពាក្យលោកថានោះ ខ្ញុំបាទហ៊ានឲ្យលោកធ្វើទោសខ្ញុំបាទដោយប្រការផ្សេងៗ"ៗ ឃុនវ៉ាតក៏យកខ្សែនោះ ទៅឲ្យជាងទងគេមើល ៗ នាយជាងទងនោះបានកាត់មើលបន្តិចទៅ ក៏ឃើញជាមាសប្រាកដ ទើបជំរាបឃុនវ៉ាតថា មាសមែនហើយលោក ចូរលោកទទួលយកទុកចុះមិនខាតទេ ទើបឃុនវ៉ាតវិលមកផ្ទះ ហើយនិយាយកត់ត្រាសញ្ញាឈ្មោះ នឹងចៅនោះព្រមចិត្តគ្នា ទើបយកប្រាក់៣០ រៀលប្រគល់ឲ្យទៅចៅនោះៗ ចៅពាលបានប្រាក់ហើយ ក៏លាឃុនវ៉ាមកទីលំនៅអាត្មាៗ លុះអស់ខែ១ ចៅពាលក៏យកប្រាក់ការមកជូនឃុនវ៉ាតនោះ តែដលើទេសកាលមានវិធីធ្វើបុណ្យឬការមង្គលប្រជុំមហាជនកាលណា ក៏យកខ្សែ



នោះពាក់ប្រដាប់អាត្មាទៅកាលនោះលុះកន្លងខែ៣ មកៗ ចៅពាលក៏យកប្រាក់៣០រៀលដើម នឹងប្រាក់ការទៅលោះខ្សែ ឃុនវ៉ាតៗក៏បានទទួលប្រាក់ហើយប្រគល់ខ្សែនោះទៅចៅពាលវិញៗ ចៅពាលក៏លាឃុនវ៉ាតមកកាន់ទីលំនៅខ្លួន លុះនៅយូរបន្តិចមក ចៅពាលយកខ្សែនោះទៅបញ្ចាំឲ្យឃុនវ៉ាតម្តងទៀត បញ្ចាំជាន់ក្រោយនោះឡើងថ្លៃ៥០រៀល ឃុនវ៉ាតក៏ទទួលបញ្ចាំដូចជាន់មុន លុះនៅយូរបន្តិចមក ចៅពាលយកប្រាក់៤០ រៀលនឹងការប្រាក់ទៅលោះយកខ្សែ អំពីឃុនវ៉ាតមកវិញៗ លុះកន្លង៥ខែមកចៅពាលធ្វើខ្សែក្រឡៃ១មានរូបសណ្ឋានភាពនូវក្បាច់ទាំងទំនងដែលជាងកាត់បន្តិចនោះ ក៏ដូចគ្នានឹងខ្សែជាន់មុនហើយ ចៅពាលយកទៅបញ្ចាំឲ្យឃុនវ៉ាតទៀតបញ្ចាំឡើងថ្លៃ៦០រៀល ៗ ឯឃុនវ៉ាតក៏ពុំបានត្រួតត្រាមើលឲ្យម៉ត់ចត់ ព្រោះខ្សែនោះដូចគ្នានឹងជាន់មុន ហើយចៅពាលយកទៅបញ្ចាំ ឃុនវ៉ាតទុកចិត្តឥតសង្ស័យទើបទទួលបញ្ចាំខ្សែក្រឡៃនោះនឹងចៅពាល បានប្រគល់ប្រាក់៦០រៀលឲ្យចៅពាលៗទទួលយកប្រាក់ហើយ ក៏លាឃុនវ៉ាតវិលទៅកាន់ទីលំនៅខ្លួនដូចដើមលុះនៅយូរបន្តិច ចៅពាលក៏យកប្រាក់៦០រៀលនឹងការ

ទៅលោះខ្សែក្រឡៀអំពីឃុនរ៉ាតៗ ក៏ទទួលយកប្រាក់ហើយទៅយកខ្សែនោះហុចឲ្យចៅពាល ៗ ទទួលយកមក ក៏ធ្វើជាពិនិត្យមើលចុងដើមខ្សែនោះហើយក្លែងនិយាយបញ្ឆកថា "ខ្សែនេះមិនមែនជាខ្សែខ្ញុំបាទទេលោក ម្តេចក៏លោកយកខ្សែក្រឡៀតែផ្លាសពីណាមកឲ្យខ្ញុំបាទច្នោះវិញ ខ្សែខ្ញុំបាទនេះមាសពិតៗលោក"ៗ ឯឃុនរ៉ាតក៏ឆ្លើយថា "ខ្សែនោះឯងហើយជារបស់ឯង យើងនឹងមានខ្សែឯណាមកលាយឡំច្រឡំគ្នានោះក៏ទេ មានតែខ្សែចៅឯងមួយប៉ុណ្ណោះឯង ហេតុម្តេចក៏ថាពុំមែនវិញដូច្នោះ យើងទៅឆីឆចៅឯងឯណាបាន"ៗ ចៅពាលក៏ថាមែនយ៉ាងរូបខ្ញុំបាទជាអ្នកទ័លក្រ មកកោងឆីឆបោកកុហកអ្វីពីលោកឲ្យខូចផ្លូវមេត្រីនោះ តែខ្សែខ្ញុំបាទមាសពិតៗដូចលោកបានឲ្យជាងសាកមើលពីដើមហើយ ក៏ឯខ្សែនេះជាខ្សែកាឡៀសោះ ខ្ញុំនឹងទទួលយកម្តេចបាន លោកយកខ្សែតែផ្លាសមកឲ្យខ្ញុំបាទយ៉ាងនេះ បើលោករកខ្សែមាសនោះពុំបានសូមឲ្យលោកសងថ្លៃខ្សែខ្ញុំបាទជាប្រាក់១៣៥រៀល"ៗ ឃុនរ៉ាតឮចៅពាលថាដូច្នោះក៏កើតទោសោខ្លាំងហើយថា "ឯងមិនសុខចិត្តយកខ្សែនេះ ក៏តាមចិត្តចុះ ឬចង់ទៅប្តឹងសាលាណាក៏តាមខ្មោចអាខ្មោច



ខ្សែផង់ឯងហើយ នៅថាមិនមែនទៀតទៅឲ្យឆាប់ទៅកុំមកតឈ្លោះអ្វីនឹងអញ"ៗ ឯចៅពាលពុំទទួលយកខ្សែ ហើយក៏ចុះអំពីផ្ទះឃុនរ៉ាតទៅពឹងចៅស្មាក្តីម្នាក់ឲ្យធ្វើរឿងរ៉ាវប្តឹងចោទយកតួឃុនរ៉ាតកោងឆខ្សែ តាមសេចក្តីគ្រប់ប្រការ ហើយចៅពាលក៏យកពាក្យនោះ ចូលទៅប្តឹងដល់សាលាចៅក្រមៗ សាលាកាល់ទទួលពាក្យបណ្តឹងនោះហើយ ទើបមានដីកាហៅរូបឃុនរ៉ាតចម្លើយមកសួរ ៗ ឯឃុនរ៉ាតក៏ធ្វើពាក្យឲ្យការឡើង តាមដំណើរអំពីដើមដល់ចុង ជូនដល់ចៅក្រម ចៅក្រមសាលាយកពាក្យចោទពាក្យចម្លើយមកជំរះទៅ ក៏យល់សេចក្តីខាងពាក្យចោទពោលអាងនាយជាងទងជាសាក្សី ទើបហៅយកសាក្សីនោះមកឲ្យស្បថជាបន្ទាល់ឲ្យការ ឯនាយជាងទងនោះក៏ឆ្លើយឲ្យការថាខ្លួនបានកាត់ខ្សែមើលជាមាសមែន ឯត្រង់ចៅពាលផ្លាស់ប្តូរលោះទៅហើយយកមកបញ្ចាំ២-៣ដងទៀតនោះជាងទងសាក្សីពុំដឹង ទើបឆ្លើយថាខ្សែនោះជាមាសពិតមែនដូចពាក្យចោទ ទើបចៅក្រមកាត់ក្តីនោះឲ្យឃុនរ៉ាតចាញ់ចៅពាល ឃុនរ៉ាតត្រូវសងថ្លៃខ្សែមាសជាប្រាក់ ១៣៥រៀលផង ត្រូវបង់ប្រដាប់ក្តីជួសចៅពាលផង សងសោហ៊ុយទាំងអស់ផងៗ

រឿងឃុនវ៉ាតបាញ់ក្តីចៅពាលនេះ ឯងស្តាប់មើលចុះជាតិមនុស្សពាលវាចេះឧបាយកល ធ្វើឲ្យឃុនវ៉ាតដល់នូវសេចក្តីវិនាស ហេតុនោះទើបថាមនុស្សបាលនេះ គួរស្ញើប គួរខ្លាចណាស់ៗ មួយទៀតពាលនេះក្រនឹងកំណត់កត់ឲ្យដឹងថា អាការកិរិយាែន មនុស្សពាលមានលក្ខណៈសណ្ឋានយ៉ាងនេះយ៉ាងនោះទៅបានៗ

ឯមនុស្សស្រុងឃើងសព្វថ្ងៃនេះ នឹងតែថាអ្នកណាផឹកស្រាជក់អាភៀន ស្លៀកពាក់សើយលាត់ ឬដើរក្រឡែក្រឡ បក្កពាក្យជំលោះប្រកែកទៅផ្សេងៗនោះទើបដឹងថា អ្នកនោះជាមនុស្សពាលមែន ឯត្រង់ពាលវាក្លែងធ្វើកិរិយា ប្រើអាការស្លៀកពាក់ទៀបរយសំដែងកិរិយាសុភាពរាបសានោះ មិនស្គាល់ឡើយ បណ្តាអ្នកនគរ ដែលរាប់អានព្រះពុទ្ធសាសនានេះតែឃើញមនុស្សកោរក្បាល ស្លៀកស្បង់ពាក់ចីពរហើយ ក៏តាំងសំគាល់ថា ជាមនុស្សត្រឹមត្រូវបរិសុទ្ធទុកចិត្តជឿរាប់អាន ដល់មនុស្សពាលវាយល់ភេទនោះហើយ ទើបវាក្លែងលួចភេទនោះមកធ្វើជាភិក្ខុឬសាមណេរ ដើរកុហកបញ្ឆោតអ្នកនគរឲ្យខូចផលប្រយោជន៍ទៅផ្សេងៗ ក៏មានដូចនិទានពីមនុស្សម្នាក់គេហៅថា ចៅពាលត្បាល់ក្លឿងតមកថាកាលនោះ មានមនុស្សស្រីម្នាក់



តាំងលំនៅៗភូមិសួនចំការ ផ្ទះនោះនៅដាច់ពីគេនាងនោះមានកូនខ្ចីអាយុប្រហែល៨-៩ ខែតាំងពីប្តីស្លាប់ទៅនាងនោះក៏មេម៉ាយនៅតែជាមួយនឹងបងប្អូន ឯកូនខ្ចីនោះពុំសូវជាប្ចូនកើតទោគគ្រុនស្កន់ជាន់ម្តងៗ កើតរីងរៃស្គមលឿងលុះនៅយូរបន្តិចមកមានមនុស្សម្នាក់ដឹងថា នាងមេម៉ាយនោះមានសម្បត្តិច្រើនទើបវាស្វែងរកមើលចន្លោះឱកាស នឹងទៅបញ្ឆោតកុហកបោកប្រាសនាងមេម៉ាយនោះ លុះដល់រដូវកាល គេច្រូតស្រូវទើបបងប្អូនញាតិមិត្រដែលនៅជាមួយផងនោះ គេនាំគ្នាទៅច្រូតស្រូវទាំងអស់គ្នា នៅតែនាងមេម៉ាយនៅចាំផ្ទះមនុស្សពាលនោះ កាលណាបានឱកាសហើយ វាក៏កោរក្បាលហើយ វាលួចយកស្បង់ចីពរលោកសង្ឃដែលគេគរបោលតាមគល់ពោធិ មកស្លៀកពាក់ធ្វើអាការកិរិយាជាលោកសង្ឃ ដើរត្រង់ទៅផ្ទះនាងមេម៉ាយនោះ លុះដល់ហើយ វាធ្វើជាដើរឈរទេរានៅមុខផ្ទះ ឯនាងមេម៉ាយនោះអង្គុយនៅរានហាលឲ្យកូនបៅដោះ លុះបានឃើញអ្នកក្លែងភេទនោះហើយ ក៏នឹកថាលោកសង្ឃបរិសុទ្ធ ទើបបីកូនចុះទៅថ្វាយបង្គំសួរថា "ព្រះករុណាម្ចាស់ និមន្តមកពីវត្តណាត្រូវការរកអ្វី ព្រះគុណ? ចៅពាលក៏ឆ្លើយទៅថា៖ "ចំរើនពរអាត្មាភាព

មកពីវត្តក្រោម មករកបិណ្ឌបាតទៀនធូបយកទៅវៀនសមណ
ធម៌ញោម អ្នកភូមិនេះគេទៅណាអស់ បានជាស្ងាត់ម្ល៉េះ?
"ករុណាម្ចាស់គេទៅច្រូតស្រូវឯស្រែអស់ហើយលោកម្ចាស់" ។
"ឱដូច្នោះហ: ញោមចុះញោមឯងមិនទៅច្រូតស្រូវនឹងគេទេ?"
"ឱ!ករុណាម្ចាស់ខ្ញុំម្ចាស់នេះទៅច្រូតកាត់នឹងគេឯណាបាន កូនតូច
នេះវាចេះតែឈឺមិនឈប់សោះឡើយ ចេះតែយំដាក់ពីដៃមិនរួច
សោះ ព្រះករុណាម្ចាស់" ។ "ចំរើនពរ ចុះវាឈឺយ៉ាងណាកូនញោម
នោះ?" ។ "អរុណាម្ចាស់អាការជម្ងឺនោះកំណត់មិនបានជួនកាលវា
គ្រុនក្តៅក្រហាយទៅ ជួនណាវាកើតជាស្កន់ជាន់គ្របបាត់ដង្ហើម
ទៅម្តងៗក៏មាន ករុណាម្ចាស់" ។ "ឱ!អាណិតវាពេកណ៎ាញោម
ជម្ងឺយ៉ាងនេះគែហៅថាស្កន់ខ្លាវាជាន់ណ៎ាញោម ម្តេចមិនរកគ្រូ
ពេទ្យឲ្យគេមើលគ្នាទៅ បណ្តោយឲ្យឈឺយ៉ាងនេះ ជម្ងឺនេះមិន
មែនជាក្រទេល្មមរក្សាបាន កូនបងអាត្មាភាពម្នាក់វាឈឺយ៉ាងហ្នឹង
ដែរ អាត្មាមើលជាទៅឥឡូវធាត់ទ្រលុកៗញោម. ឱ!ស្តាយកូន
ញោមនេះពេកណាស់ប្រុសផងគួរតែខំមើលរក្សាទៅអេះ" ។
"ករុណាម្ចាស់គ្រូនោះបានឲ្យគេមើលក៏ច្រើនអ្នកណាស់ហើយ
បានគ្រាន់តែ២-៣ថ្ងៃ ក៏ត្រឡប់ឈឺដូចដើមវិញករុណាម្ចាស់" ។



"ឱ! គ្រូមើលជម្ងឺកូនក្មេងនោះគ្រាន់តែស្តោះផ្លុំតែពីក្រៅធ្វើម្តេ
ចនឹងជាដាច់រោគស្កន់ខ្លានេះបាន តោងមើលដោយឧបទេស
ទើបជាដាច់ញោម, អាត្មាចេះខ្លះដែរតែអាត្មាដែលមកនេះ
ដោយមានកិច្ចរកទៀនធូបបានហើយ ក៏នឹងអាលទៅវៀនសម
ណធម៌ បើនៅជិតវត្តអាត្មាទៅវ៉ានឹងជួយសង្គ្រោះមើលយក
បុណ្យខ្លះ" ។ ឯនាងមេម៉ាយនោះលុះឮចៅពាលពោលពាក្យ
ដូច្នោះហើយ ក៏សំគាល់ថា ជាលោកអ្នកចេះមើលជម្ងឺមែនទែន
ទើបនិយាយអង្វរថា ព្រះករុណាម្ចាស់បើលោកម្ចាស់ចេះ សូម
មេត្តាប្រោសសត្វ មើលកូនខ្ញុំករុណាសិនឯត្រង់ទៀនធូបដែល
លោកម្ចាស់ត្រូវការនោះ មិនជាប៉ុន្មានទេខ្ញុំករុណាថ្វាយខ្លួន ជា
ញោមឧបដ្ឋាកបវារណាលោកម្ចាស់ សូមកុំឲ្យលោកម្ចាស់ព្រួយ
ព្រះហឫទ័យឡើយ ។ ឯចៅពាលនោះបានឱកាសហើយក៏ឆ្លើយ
ថា "ចំរើនពរញោម ធ្វើម្តេចឯងជាសង្ឃកំពង់សត្វកាលបើ
ឃើញញាតិញោមកើតវិបត្តិ តោកាត់ធុរៈខ្លួនសិនចុះ ថាហើយ
ក៏ឡើងទៅលើផ្ទះ ។ ឯនាងមេម៉ាយក៏រៀបទីអាសនៈដ៏សមគួរ
ឲ្យចៅពាលអង្គុយ ហើយក៏បៀកស្លាម្លូបារីដាក់ពាន ប្រគេន
ចៅពាល ចៅពាលក៏បង្គាប់ឲ្យនាងមេម៉ាយរៀបទៀន៥ ធូប៥

ឆ្នាំងថ្មីមួយនិងសំពត់ស១ ចំអាមទាញយន្តបិទមាត់ឆ្នាំងហើយចៅពាលថា "ញោម, ទីភូមិនេះមានត្បាល់ក្លៀងដែរឬ? "ករុណាម្ចាស់, ត្បាល់ក្លៀងខ្ញុំករុណាមាននៅខាងកន្ទៀផ្ទះឯនោះ ៗ "អើញោមបើដូច្នោះយកកូននិងគ្រឿងទៀនធូបអស់នេះ ទៅឯរោងក្លៀង អាត្មានិងរៀបពិធីក្លៀង"ៗ នាងមេម៉ាយក៏បីកូនកាន់យកទៀនធូបអស់នេះទៅឯរោងក្លៀង ហើយចៅពាលយកទៀនធូប អុជតាំងពិធីនៅមាត់ត្បាល់ហើយវាបោសទីនោះស្អាតល្អ ពុំឲ្យមានឈើព្រៃនៅខាងក្បាលទើបវាហៅយកកូនខ្ចីនោះមកតាំងខាងនាទីពិធីហើយវាថា ញោមឯងទៅដាន់ចុងក្លៀងឲ្យឡើងដាន់ដាក់ជន្លៗបាន៣ ដងជាឧបកិច្ច អាត្មានឹងសែកព្រះគាថា ស្រូបយកព្រលឹងខ្លាចេញពីរូបកូនបញ្ចូនដាក់ក្នុងឆ្នាំយន្តហើយយកទៅបណ្តែតទឹកចោលដើម្បីកុំឲ្យព្រលឹងខ្លាវាមកបៀតបៀនបានទៀតឡើយឯនាងមេម៉ាយក៏ជឿតាម ទើបទៅដាន់ចុងក្លៀងឡើងឯចៅពាលវាយកកូននោះ ដាក់ទៅក្នុងត្បាល់ហើយវាដកឈើទ្រនល់ដែលទល់ក្លៀងនោះ បោះគ្រវែងចោលទៅឆ្ងាយអំពីត្បាល់ ហើយវាដើរចេញពីទីពិធីនោះប្រាប់ទៅថា ញោមប្រុងដាន់ឲ្យជាប់កុំឲ្យប្រហែសក្រែងរបូតជើងធ្លាក់



ទៅត្រូវកូន ចាំអាត្មាទៅយកថង់យាមចាន់ស្លាមួយទំពេចសូមមកទល់ឲ្យវិញ ថាហើយចៅពាលក៏ឡើងទៅលើផ្ទះ តាំងរើរករបស់ទ្រព្យមាសប្រាក់កែវកង សំពត់អាវស្បៃហើយវាវេចជាសំពាយធំ តាំងស្ពាយពីលើផ្ទះរត់ទៅកាន់លំនៅវាហោងៗ

ឯនាងមេម៉ាយ ឃើញចៅពាលដញ្ជូនយកទ្រព្យសម្បត្តិខ្លួនដូច្នោះហើយក៏ហៅឲ្យគេជួយក៏ពុំមានអ្នកណាមួយឮឡើយព្រោះផ្ទះនោះនៅដាច់អំពីគេ ម្លោះហើយនាងមេម៉ាយក៏អន្ទះអន្ទែង នៅចុងក្លៀងនោះឯង បើនឹងលែងក្លៀងចេញទៅខ្លាចធ្លាក់ទៅត្រូវកូន ដោយចិត្តមាតាតែងទន់ទោរចុះទៅកាន់កូនអាត្មាជាធម្មតា ការដែលសោកស្តាយទ្រព្យសម្បត្តិក្រៅក៏ជាមធ្យម ឯសេចក្តីដែលលោកអាណិតកូននោះ លើសលែងសម្បត្តិខាងក្រៅ នាងមេម៉ាយក៏នៅប្រងាងដូចបុគ្គលគេចងភ្ជាប់រេតែខ្លួនក៏ពុំរួច លុះដល់ពេលល្ងាច ទើបមានគេដើរមក ទើបឲ្យគេដល់បន្ទល់ក្លៀងយកកូនបានៗ

អាសូរនាងមេម៉ាយកាយជាប់ក្លៀង ព្រោះអាចោរសំពត់លឿងវាបញ្ឆោត សែនក្តួលសែនក្តៅសែនក្រេវក្រោធនឹងលោតទៅតាមចាប់អាចោរ ៗ ក្រែងក្លៀងត្រូវកូនសូន្យជីវិត

ដោយចិត្តមាតាតែងទន់ទោរ តែមានអារម្មណ៍ឲ្យខឹងឃោរ នឹងបោលបង់កូននោះពុំមាន ។

និទាននេះមានដំណាលក្នុងក្បួនសៀម ។

(ស) សួរថា អាការមនុស្សពាលដែលសំដែងមកនោះតើមានយ៉ានណាខ្លះទាន?

(ត) តបថា ឯមនុស្សពាលដែលសំដែងអាការចេញនោះមានច្រើនប្រការណាស់វាខ្លះ វាប្រើកិរិយាសង្រួមហួសប្រមាណ ខ្លះវាព្រួហ៍បំភ័យខ្លះពោលអួតវិជ្ជាចំណេះ ដែលខ្លួនវាពុំមានតែបើមានប្រាជ្ញាពិចារណា តាមអាការវាក៏គង់យល់ខ្លះមិនខាន ។

## តម្រាពាលសង្រួមហួសប្រមាណ

ដូចនិទានពីតាបស១រូប ទៅតាំងអាស្រមកុដិនៅខាងជាយព្រៃ១នៅទៀបជនបទនោះ ។ មានឧបាសកម្នាក់ជាអ្នករាប់អានតាបសនោះបានថ្វាយខ្លួនជាអ្នកឧបដ្ឋាកជាអ្នកបំរើ ។ ឯតាបសនោះតែងចូលទៅកាន់ត្រកូលនោះរឿយៗ លុះនៅយូរមកឧបាសកនោះយកប្រាក់១ហិបទៅផ្ញើទុកនឹងតាបស ។ ឯតាបសក៏ឲ្យឧបាសកកប់ហិបប្រាក់ទុកក្នុងទី១ ដ៏សមគួរខាងទីអាស្រមនោះឯង ដល់នៅយូរបន្តិចមកតាបសនោះកើតលោភចេតនា



ទើបគិតថាអាត្មាអញនេះមកបួសខំប្រព្រឹត្តរក្សាសីល ក៏យូរឆ្នាំណាស់ហើយមគ្គក៏មិនបានដល់ ផលក៏មិនបានសម្រេចទាំងឈានទៀតក៏មិនកើតម្តងសោះ បើដូច្នោះគួរតែអញសឹកចេញចាកសិក្ខាទៅជាឃរាវាសវិញ គិតប្រកបការរកស៊ីយលជាប្រសើរជាង ឯប្រាក់ដែលឧបាសកគេផ្ញើរនោះអញនឹងលួចយកទៅធ្វើជាដើមទុន ប្រកបការខាងផ្លូវលោកិយបានហើយតែនឹងលួចយកទៅឥឡូវនេះឧបាសកជាម្ចាស់ គេនឹងតាមតវ៉ាចោទថាអាត្មាលួចបើដូច្នេះ មានតែគិតលួចជាការបង្វែងដាន កុំឲ្យម្ចាស់គេនោះសង្ស័យនឹងខ្លួនអញបាន, កាលបើតាបសគិតយល់ឧបាយ១ដូច្នោះហើយ ទើបកកាយយកហិបប្រាក់អំពីទីនោះ នាំទៅកប់ទុកទីដទៃ ដើម្បីមិនឲ្យម្ចាស់ប្រាក់សង្ស័យនឹងខ្លួន លុះកប់លាក់ហិបប្រាក់នោះស្រេចហើយ តាបសក៏រៀបគ្រឿងបរិក្ខារដាក់សំពាយស្ពាយដើរទៅកាន់ផ្ទះឧបាសក ។

ឯឧបាសក បានយល់តាបសមកដូច្នោះហើយក៏រៀបទីអាសនៈដ៏សមគួរ ហើយនិមន្តតាបសឡើងទៅលើគ្រឹះស្ថាន វន្ទាធ្វើបដិសណ្ឋារៈសួរទទួលដោយសេចក្ដីរាប់អាន ។ ឯតាបសនិយាយថា៖ "ចំរើនពរអាត្មាភាពមកលាញោមទាំងអស់គ្នា នឹងទៅនៅព្រៃ

ព្រះហិមពាន្តហើយ ត្បិតទីលំនៅសព្វថ្ងៃនេះជាទីនៅជិតទៀប
ស្រុកមនុស្សម្នាទៅមកមិនដាច់ នាំឲ្យកង្វល់រវល់នឹងការលោកិ
យច្រើនណាស់ រកឱកាសនឹងចំរើនមេត្តាភាវនាពុំបាន, ១ទៀត
រឿងប្រាក់ញោមដែលផ្ញើរនោះ ឲ្យញោមទៅយកផងចុះ
អាត្មាទៅហើយក្រែងមានអន្តរាយជាខាងក្រោយ ញោមកុំមែ
ថាអាត្មាឡើយ"។ ឯឧបាសកនោះក៏ឆ្លើយថា "មិនអីទេ ព្រះករុ
ណារឿងប្រាក់ដែលកប់លាក់ទុកនោះចំពោះដឹងតែលោកម្ចាស់
នឹងខ្ញុំករុណាតែពីរនាក់ប៉ុណ្ណោះឯង អ្នកឯណានឹងបានដឹងឮផង
ជា៣ ៤ នាក់ពុំមាន បើលោកម្ចាស់ចង់ទៅនៅព្រៃហិមពាន្តក្នុង
ថ្ងៃណា ក៏សូមនិមន្តទៅចុះរឿងប្រាក់នោះចាំខ្ញុំរួចធុរៈរវល់
ថ្ងៃណាសឹមខ្ញុំទៅយក"។ ឯតាបសក៏ឆ្លើយថា "ចំរើនពរអញ្ជើ
ញទៅយកចុះ" ថាហើយក៏លាត្រកូលនោះចេញទៅ កាលចុះ
ទៅដល់មាត់ជណ្ដើរ តាបសក៏កាន់យកស្បូវដែលប្រក់ផ្ទះនោះ
មួយសរសៃ ហើយសៀតជាប់និងជដា គឺផ្នួងសក់ដើរទៅដល់
មាត់ច្រកផ្លូវ ហើយវិលត្រឡប់មកវិញលើកយកកំណាត់ស្បូវ
នោះជូនទៅឧបាសកហើយថា "ញោមអើយអាត្មាភាពសូមទោ
សញោមផងចុះត្បិតអាត្មាពុំបានក្លែងលួចកំណាត់ស្បូវនេះទេ



គឺវាជាប់ទៅនឹងផ្នួងជដានៃអាត្មាៗពុំដឹងសោះ លុះតែដើរទៅ
ដល់ក្រៅរបង ស្រាប់តែឃើញស្បូវនេះវាធ្លាក់ពីជដាមក ទើប
អាត្មាកើតសេចក្ដីភិតភ័យដោយសីល ក្រែងសៅហ្មង ហេតុនេះ
ទើបយកមកជូនញោមវិញ សូមញោមមេត្តាអត់ទោសអាត្មា
ចុះ"។ ឯឧបាសកនោះលុះឮពាក្យជដិលកោងនិយាយជូនកំណាត់
ស្បូវដូច្នោះហើយ ក៏សំគាល់ថា "លោកតាបសនេះមានសីលពិ
សេស" ទើបតបទៅថា "បពិត្រព្រះករុណាម្ចាស់ កុំមានហឫទ័យ
វង្កៀសឡើយ ឃើងខ្ញុំពុំមានចិត្តសង្ស័យនឹងសីលលោកម្ចាស់ទេ
ចូរលោកម្ចាស់និមន្តទៅតាមសប្បាយចុះ"។

គ្រាកាលនោះ ព្រះពោធិសត្វជាម្ចាស់យើងនេះអន្ទោលជាតិ
កើតជានាយឈ្មួញ១នាក់ បានទៅជួញដល់ទៅស្រុកនោះ លុះ
ដើរទៅបានឮតាបសជូនកំណាត់ស្បូវ ដែលខ្លួនកាន់យកដោយ
ឧបាយកោងដូច្នោះហើយក៏យល់ដោយប្រាជ្ញាជ្រាបថា តាបស
នេះមានបើលួចយកទ្រព្យអ្វីៗ របស់អ្នកផ្ទះនេះមិនខានឡើយ
ទើបពោធិសត្វដណ្ដឹងសួរទៅឧបាសកនោះថា "អ្នកឯងមានផ្ញើ
ទុកដាក់របស់អ្វី នឹងតាបសនេះខ្លះដែរឬទេ"។ ឧបាសកនោះ
ប្រាប់ថា៖ "ខ្ញុំបាទផ្ញើប្រាក់១ហឹបនឹងលោក"។ ពោធិសត្វថា

"ឱ! បើដូច្នោះប្រាក់អ្នកឯងនោះវិនាសដោយដែលោកជីគុនអ្នកប្រាកដហើយ ប្រាក់១ហឹបនោះលោកជីគុនអ្នកឯងលួចយកទៅហើយ ចូរអ្នកឯងទៅតាមចាប់ខ្លួនឲ្យទាន់ក្នុងកាលឥឡូវនេះ ៗ

ឯឧបាសកជាមនុស្សឥតប្រាជ្ញា ក៏ឆ្លើយតបថា "លោកជីគុនខ្ញុំនេះ លោកមានសីលវិសេសពេកណាស់លោកនឹងអាចហ៊ានលួចប្រាក់នោះឯណាបានតែត្រឹមកំណាត់ស្បូវ១សរសៃ ដែលជាប់ទៅនឹងជដាសក់របស់លោក ម្ដេចលោកក៏ពុំហ៊ានកន្លងលោកនាំយកមកឲ្យវិញ ហេតុនោះនឹងថាលោកលួចប្រាក់ខ្ញុំឯណាបាន" ៗ

ពោធិសត្វតបថា "ឱ! អ្នកឯងមិនស្ដាប់អាការពាលទេតើ! នែអ្នក, ក៏ឯសីលអទិន្នាទាននឹងដាច់នឹងសៅហ្មង ព្រោះកំណាត់ស្បូវ១សរសៃនោះឬអីនេះឯងហើយ ជាអាការរបស់មនុស្សយកសក់បាំងភ្នំបន្លំដាន លួចប្រាក់អ្នកឯងពិតហើយ បើអ្នកឯងមិនជឿអញ្ជើញទៅមើលប្រាក់អ្នកចុះ ដែលផ្ញើទុកនោះជានៅដូចដើមឬដូចម៉េចទៅ ចូរទៅឲ្យឆាប់ ទាន់តាបសគាត់មិនទាន់ទៅឆ្ងាយ" ៗ ឯឧបាសកនោះក៏យល់តាមទើបនាំពោធិសត្វទៅអាស្រមនៃតាបស ទៅមើលទីដែលកប់ប្រាក់នោះ



ឃើញអាចម៍ដីខ្វាយវាយពាសទើបកកាយទៅខាងក្រោម ក៏ពុំឃើញហឹបប្រាក់នោះឡើយ ៗ ឧបាសកក៏រឹតតែជឿពាក្យពោធិសត្វក្រៃពេកទើបនាំពោធិសត្វរត់ទៅតាមតាបស បានទាន់នាកណ្ដាលផ្លូវ ហើយក៏ចាប់ខ្លួនតាបសនោះមកសាកសួរថា ប្រាក់យើងដែលផ្ញើនោះបាត់អស់ទៅហើយកាលយើងមកកប់ទុកនោះ ពុំមានអ្នកណា១ អាចដឹងទេ គឺដឹងតែប្រស្ដែងឯងនិងរូបយើងពីរនាក់ប៉ុណ្ណោះទេ ឥឡូវបាត់ពីទីនោះទៅ នឹងថាអ្នកឯទៀតណាមកលួចនោះក៏មិនបាន គឺប្រស្ដែងឯងលួចពិតហើយ ចូរអ្នកប្រាប់យើងដោយពិតចុះ បើពុំប្រាប់យើង យើងនឹងវាយឲ្យស្លាប់ឥឡូវនេះឯង ៗ ឯជដិលកោងនោះក៏ភិតភ័យខ្លាចសេចក្ដីស្លាប់ ក៏ប្រាប់តាមដំណើរខ្លួនលួចបង្វែងទៅកប់ទុកនៅទីឯទៀត ហើយក៏នាំឧបាសកនោះ ទៅយកហឹបប្រាក់ដែលខ្លួនលាក់ទុកនោះប្រគល់ឲ្យដល់ឧបាសកជាម្ចាស់ប្រាក់" ៗ ឯឧបាសកក៏ទទួលយកហឹបប្រាក់ ហើយតិះដៀលតាបសនោះដោយប្រការផ្សេងៗ ហើយបែរទៅសរសើរប្រាជ្ញានៃពោធិសត្វ ដោយអនេកបរិយាយ ទទួលពោធិសត្វទុកជាគ្រូអាចារ្យប្រដៅខ្លួនអំពីថ្ងៃនោះមក ៗ

ចប់តម្រាពាលសង្រួមហួសប្រមាណ

(ស) ឆ្លើយថាករុណាលោកគ្រូម្ចាស់ៗសំដែងមកនេះខ្ញុំចូលចិត្តហើយ តែការដែលនឹងស្គាល់អាការកិរិយាមនុស្សពាលនោះក្រណាស់ ចួនមនុស្សពាលនោះ វាមានអំណាចនិយាយបញ្ចុះបញ្ចូលអ្នកស្រុកអ្នកស្រុកក៏នាំគ្នាជឿតាមពាលនោះទៅចួនជាមានអ្នកណា១ ដឹងស្គាល់អាការកិរិយានៃមនុស្សពាល នៅមិនប្រព្រឹត្តមិនជឿតាមគេៗ ក៏បៀតបៀនអ្នកនោះឯងថាជាមនុស្សឆ្កួតវិញ ដូច្នេះនេះលោកគ្រូនឹងប្រព្រឹត្តទៅយ៉ាងណា នឹងឲ្យរួចអំពីពាលនោះបាន?។

(គ) ឱ! ឯងថានោះត្រូវហើយ ក៏វិស័យគេឆ្កួតពេញស្រុកហើយ ឯងជាតែម្នាក់ឯងឯណាក៏នឹងបានតែតោងមើលកាល មើលសម័យពិចារណាមើលតាមអាការនោះផង ជាការពាក់ព័ន្ធដោយទោសរាជឬដោយទោសរាស្ត្រ គឺកើតមកជាមនុស្សត្រូវឲ្យស្គាល់ទោសពីរប្រការ គឺទោសរាជ១ ទោសរាស្ត្រ១ ឯទោសរាជនោះ គឺពាលនោះឯងវាក្លែងតាំងខ្លួនជាអ្នកបុណ្យ ហើយអួតខ្លួនថាវាជាស្តេច ជាព្រះអង្គម្ចាស់ មាននាមថាព្រះបាទធម្មិករាជជាដើម តាំងបញ្ចុះបញ្ចូលមហាជនជាកងទ័ព គិតក្បត់ម្ចាស់ផែនដីយ៉ាងនេះហៅថា ទោសរាជគឺទោសព្រោះតាំងខ្លួនជាស្តេចថា



បើឯងដឹងអាការហេតុដូចយ៉ាងថាមកនេះហើយ តោងគិតវេះគេចចេញចាកទីនោះបង់ ទើបអាចរក្សាខ្លួនឲ្យសុខបាន។

ឯទោសរាស្ត្រនោះ គឺពាលមានអំណាចក្តី ឥតអំណាចក្តី វាប្រចុចប្រចែងក្លែងក្លាយ ប្រើឧបាយមាយានិយាយអួតកុហកថាវាចេះធ្វើហោរទាយ ចេះអង្គុយធម៌មើលហួយ មើលខ្មោចចេះគ្រូមើលជម្ងឺ មើលស្តោះគ្រោះ បូជាគ្រោះជាដើមហើយវានិយាយបំភ័យឲ្យអ្នកស្រុកបូជាផ្សេងៗ។ មនុស្សទាំងឡាយជឿវាពេញស្រុកហើយ តែឯងមិនជឿតាមគេៗថាឯងឆ្កួតយ៉ាងនេះហៅថាទោសរាស្ត្រ។ តែបើពាលមានអំណាចវានឹងបៀតបៀនហើយ តោងប្រព្រឹត្តទៅតាមកិរិយាដូចតម្រាថា "លោតប្រែតោងប្រព្រឹត្ត តែចិត្តកុំប្រែតាមវា" គឺប្រព្រឹត្តតែកិរិយាក្រៅទៅចុះ ព្រោះការទាល់ ដូចមាននិទានរឿងចៅសនជាបែប។

ឯរឿងចៅសននោះ ដើមឡើយមានសាមណេរ១អង្គ អ្នកស្រុកគេតែងហៅលោកតាថេនៗ នោះជានេនខ្ជិលខ្ជា លួចមាន់វត្តស្ងោរ ផឹកស្រា សុំបាយល្ងាចតែរឿយៗ មានមនុស្ស៣នាក់រួមចូលផឹកស៊ីជាមួយផង។ លុះនៅយូរមក តាថេនរកប្រាក់នឹងទិញស្រាពុំបាន ហើយគិតក្រែងនៅយូរទៅ អ្នកស្រុកគេដឹងថា

នេនផឹកស្រាគេនឹងបណ្តេញបំបរចាកអារាម ទើបនិយាយ
ពិគ្រោះគ្នានឹងមនុស្សទាំង៣ នាក់នោះថាយើងនៅក្នុងស្រុកធំ
នេះ អត្តខាត់ប្រាក់ចាយណាស់ឧបាសក ឧបាសិកាញោមវត្តនេះ
គេក៏ពុំមានសទ្ធាធ្វើបុណ្យធ្វើទាននឹងយើងឡើយ ៗ បើដូច្នេះ
គួរយើងចេញទៅស្រុកក្រៅ ដើរកែខៃកុហកបញ្ឆោតអ្នក
ស្រុកស្រែចំការដោយឧបាយផ្សេងៗ គឺអញធ្វើជាលោក
ធុតង្គរុក្ខមូល ចៅឯង៣នាក់ធ្វើជាកូនសិស្ស ឧបដ្ឋាកដើរតាម
ក្រោយ ដើរនិយាយបញ្ចុះបញ្ចោលបបួលពួកអ្នកព្រៃ ឲ្យគេ
ជឿថាអញវិសេស គេក៏នឹងនិមន្តធ្វើបុណ្យទាន បានចតុប្បច្ច័យ
ហើយសូមហើយកែខៃទិញបាយទិញស្រាផឹកទៅតាមកាល ៗ
ឯមនុស្សទាំង៣នាក់នោះក៏យល់ព្រមតាមតាថេន ក៏រៀបរក
ឆ័ត្រមុងធុតង្គ នូវគឿងបរិក្ខារបានព្រមហើយ ទើបនាំមនុស្ស
៣នាក់នោះចេញចាកស្រុកធំ ដើរទៅកាន់ស្រុកលើ តាថេន
ក៏ក្លែងខ្លួនជាលោកសង្ឃធុតង្គដោយព្រៃ ដល់វេលាព្រឹកក៏ចូល
ទៅបិណ្ឌបាតក្នុងស្រុកតាមលំដាប់ផ្លូវ ឯបណ្តាមហាជនអ្នកស្រុក
ក្រៅ កាលបើបានឃើញតាថេននោះហើយ ក៏នឹកស្មានថាជា
លោកសង្ឃរុក្ខមូលដោយសុចរិត ទើបនាំគ្នាដាក់បាតប្រគេន



ចតុប្បច្ច័យផ្សេងៗអ្នកខ្លះនិមន្តឆាកមហាបង្សុកូលអ្នកខ្លះនិ
មន្តដារចាន់ធ្វើបុណ្យផ្សេងៗ តាមសទ្ធាអ្នកកាន់ព្រះពុទ្ធសាស
នា ៗ តាថេនបានលាភសក្ការៈហើយ ក៏ធ្វើជាសង្រួមឥន្ទ្រិយស្រ
គត់ស្រគំ ពុំសូវនិយាយស្តីអ្វីច្រើនឡើយ ៗ ឯមនុស្ស៣នាក់
នោះតែទៅដល់ទីណា វាក៏នាំនិយាយសរសើរអួតគុណតាថេន
ប្រាប់អ្នកស្រុកនោះថា លោកគ្រូយើងនេះលោវិសេសខាងផ្លូវ
ក្នុងពេកណាស់ ទាំងទឹកមន្តក៏ពូកែ ចេះទាំងឃឹតមើលហួយមើល
ប៉ោក៏ឆុតឆាប់តែលោកជាអ្នកសន្តោស មិនមានសេចក្តីលោ
ភាទេបើអ្នកណាត្រូវចិត្តលោកៗ ក៏ប្រោសឲ្យទានបានសំរេច
ប្រយោជន៍គ្រប់ប្រការ ពួកយើង៣នាក់ក៏ឧស្សាហ៍ដើរតាម
លោកទាំងម្ល៉េះនេះ ព្រោះឃើញសិល្បវិជ្ជាការនោះមែនទែន
ណាស់ ៗ ឯពួកមហាជនទាំងឡាយ កាលបើបានស្តាប់ពាក្យអ្នក
ទាំង៣នាក់ស្រដីអួតតាថេនដូច្នោះហើយ ក៏ជឿតាមទើបនាំគ្នា
និមន្តតាថេនសូត្របូជាព្រះគ្រោះខ្លះ សូមទឹកមន្តខ្លះសូមខ្សែក
ខ្សែចង្កេះខ្លះ, តាថេនក៏បានលាភសក្ការៈបរិបូណ៌ដោយពួកអ្នក
ក្រៅរាប់អាន តែដល់ពេលយប់ស្ងាត់ទៅ៣នាក់ វាទៅលួចទិញ
ស្រាទិយបាយមកលៀងគ្នាក្នុងព្រៃ តាមវិស័យកិរិយាពាល ៗ

ឯតាថេននឹងអ្នក៣នាក់ វាប្រព្រឹត្តការកោងយ៉ាងនេះរៀងៗទៅតាមផ្លូវៗ លុះថ្ងៃ១តាថេននាំគ្នាទាំង៣នាក់ ដើរទៅដល់ភូមិគោក១ ទើបចូលទៅកាន់ភូមិនោះ ហើយទៅអង្គុយក្រោមម្លប់ដើមស្វាយខាងជើងភូមិៗ ឯចោរ៣នាក់វានាំគ្នាចូលទៅក្នុងភូមិនិយាយឃោសនាប្រាប់អ្នកស្រុកថា លោកធុតង្គនិមន្តមកគង់នៅខាងចុងភូមិនោះឯង បើបងប្អូនត្រូវការប្រាថ្នាការអ្វីៗក៏ចញ្ជើញយកទឹកតែ ស្ករស ស្លាបារីទៅប្រគេនលោកចុះ លោកនិមន្តមកនេះ គឺមកចង់ប្រោសសត្វហើយ អ្នកណាចង់បានខ្សែចង្កេះ ទឹកមន្តការពាររោគអាសន្នកម្មផ្សេងៗ ក៏សូមអញ្ជើញទៅរកលោកឲ្យឆាប់ចុះៗ ឯបណ្តាមហាជនប្រុសស្រីនៅទីភូមិនោះ លុះឮថាលោកធុតង្គរុក្ខមូលវិសេសមកដូច្នោះហើយ ខ្លះក៏បានស្លាបារី ខ្លះក៏បានទឹកក្តៅ ទឹកត្រជាក់នាំគ្នាទៅរកតាថេន ដល់ហើយក៏ថ្វាយបង្គំសួរទទួលបដិសណ្ឋារៈប្រគេនទុកស្រង់ទឹកឆាន់ ស្លាម្លូភេសជ្ជៈតាមសទ្ធា ហើយសំពះសួរថា ព្រះករុណាម្ចាស់និមន្តមកពីស្រុកណា ព្រះករុណាៗ

តាថេនឆ្លើយថា "ចំរើនពរ អាត្មាភាពនេះនៅក្នុងក្រុងចេញមកធុតង្គយូរខែហើយ នៅតែក្នុងព្រៃមិនដែលចូលស្រុកណា



ទេញោម ទើបតែថ្ងៃនេះ មានហេតុជាការមិនស្រួលនៅស្រុកញាតិញោមនេះបានជាអាត្មាភាពខំឧស្សាហ៍ដើរមកនេះ"ៗ ឯពួកអ្នកស្រុកនោះ លុះឮតាថេនថាដូច្នោះហើយ ក៏កើតសេចក្តីសង្ស័យឡើងគ្រប់គ្នា ទើបនាំគ្នាសួរតបថា "ករុណាម្ចាស់មានពុទ្ធធិកានេះយល់ប្លែកពេកណាស់" ចុះលោកម្ចាស់ យល់ហេតុភូមិយើងនេះមិនស្រួលយ៉ាងណា? តាថេនថា "ញាតិញោមអើយ អាត្មាអង្គុយធម៌យប់មិញនេះ ក៏ឃើញហេតុអន្តរាយនឹងកើតមានដល់ញាតិញោម ក្នុងភូមិនេះទាំងអស់គ្នាគឺឃើញថា ភូមិនេះនៅតែ៧ថ្ងៃទៀត នឹងមានអសនីបាត គឺរន្ទះបាញ់មកត្រូវភូមិនេះ ដល់នូវសេចក្តីវិនាសសូន្យទាំងភូមិជាម្តង អាត្មាគិតអាណិតដល់ញាតិញោមរាល់គ្នាណាស់ បានជាខំឧស្សាហ៍មកនេះប្រាថ្នានឹងប្រាប់សេចក្តីនោះ ឲ្យញាតិញោមបានដឹងខ្លួនជាមុនថាបើញោមឯណាចង់ឲ្យរួចអំពីកាឡកិណី សេចក្តីវិនាសនោះមានតែរើផ្ទះសំបែងចេញអំពីទីចាស់ទៅតាំងនៅភូមិក្រៅជាថ្មីទៀត នោះទើបបានផុតភ័យអំពីអសនីបាតនោះបាន"ៗ ឯបណ្តាមហាជនទាំងឡាយនោះ លុះឮតាថេនថាដូច្នោះហើយក៏កើតសេចក្តីភិតភ័យទាំងអស់គ្នា ទើបថា "សូមទានករុណាម្ចាស់

បើដូច្នោះសេចក្តីភ័យនោះនឹងមានដល់យើងខ្ញុំហើយ តែថាជាការលំបាកណាស់បើដូច្នោះករុណាម្ចាស់នឹងមានឧបាយកលល្អម ឧបទេសកែខែសេចក្តីអន្តរាយអំពីរន្ទះនោះ ជាបានខ្លះឬទេ? "ឱញាតិញោមចង់គិតកែខែឧបទេសនោះ ចាំអាត្មាអង្គុយធម៌ មើលសិន" ថាហើយ តាថេនតាំងអុជទៀនធូប ហើយតាំងសមាធិអង្គុយធ្មេចភ្នែកបានតិច ក៏បើកភ្នែកហើយថា "បានញោម តែត្រូវខាតទុនខ្លះទើបអាចធ្វើបាន"។ ករុណាម្ចាស់មិនអីទេ ទោះបងខាតធនធានប៉ុន្មានៗ ក៏មិនថាដែរធ្វើម្តេចឯងដល់នូវសេចក្តីវិនាសហើយ សូមនិមន្តលោកគ្រូម្ចាស់បង្គាប់ចុះ"។ តាថេនក៏ធ្វើជាមាយាហើយប្រាប់ថា "ឱញាតិញោមអើយអាត្មានេះជាសង្ឃផង នឹងបង្គាប់បញ្ជាទៅក៏ដូចជាមិនគួរនឹងភេទឯងជាសមណៈនោះសោះ ត្បិតភ្លើងរន្ទះនោះ តាមបាលីថាអសនី គឺថាអសុភាប្រែថាយក្ខខ្មោច។ នោះវាគាប់ចិត្តតែនឹងស្រា បាយសាច់ ញាំភ្លា មាន់ស្ងោររៀបបូជាពលិការវា ហេតុនោះបានជាថាអាត្មាទាល់ណាស់ ព្រោះឯងជាលោកសង្ឃ"។ "ករុណាម្ចាស់ កុំព្រួយព្រះហឫទ័យឡើយ និមន្តបង្គាប់ចុះយើងខ្ញុំនឹងធ្វើតាម"។ តាថេនបានឱកាសដូច្នោះហើយក៏ឲ្យធ្វើរោងពិធី១ ខ្នងនៅក្រៅ



ភូមិហើយឲ្យធ្វើរាជវតិ ទង់ ឆ័ត្រ ស្លាធម៌ បាយសី ជមបារ គ្រឿងចំអាបបង្អែមផ្សេងៗយកទៅតាំងនៅរោងពីធី។

ឯមនុស្សទាំងឡាយ ក៏នាំគ្នាធ្វើតាមពាក្យតាថេននោះសព្វប្រការ ឯតាថេនក៏នាំគ្នា៣នាក់ចូលទៅក្នុងរោង ហើយយកអម្បោះចងព័ទ្ធសីមា៧ ជាន់ហើយប្រាប់អ្នកស្រុកថា ញាតិញោមទាំងអស់នេះសុទ្ធសឹងមនុស្សមានគ្រោះធំ ត្រូវតែនៅក្រៅរោងពិធីនេះ តាថេនថាហើយទើបសរសេរសំបុត្របិទនៅមាត់ទ្វារនោះថា កុំឲ្យនរណាចូលក្នុងរោងពិធីនេះឡើយ ថាបើនរណាតាក់អម្បោះសីមាកន្លងចូលដល់ក្នុងរោងហើយអ្នកនោះនឹងទៅជាឆ្កួតឈឺស្លាប់ កើតវិបត្តិផ្សេងៗ។ បណ្ដាអ្នកស្រុកធ្វើតាមតាថេនហាមទាំងអស់ នាំគ្នាហាមកូនចៅក្មេងតូចធំ កុំឲ្យចូលទៅក្នុងរោងពិធីនោះ។

ឯតាថេនបានឱកាសស្ងាត់ហើយ ក៏នាំគ្នាទាំង៣ នាក់ស៊ីបាយផឹកស្រាតាមអំពើពាលលុះស្រវឹងស្រាខ្លាំង ក៏តាំងនិយាយកោកៗ ប្រកែកគ្នាទៅវិញទៅមកគឹកកងក្នុងរោង លុះដល់នៅបានពីរបីថ្ងៃ មានក្មេងប្រុសម្នាក់អាយុ ១៤ ឬ ១៥ឆ្នាំ ឈ្មោះចៅសនក្មេងនោះវាទៅឃ្វាលក្របីនៅវាលស្រែ។ ដល់ពេលថ្ងៃល្ងាច

ត្រដាក់ចៅសនវាដេញក្របីទៅផ្ទះ បរទៅខាងរោងពិធីនោះ
បានឮសំឡេងចៅពាលទាំង៤ នាក់ផឹកស៊ីប្រកែកគ្នាកោកកាក
ដូច្នោះហើយ ចៅសនគិតថាសំឡេងយ៉ាងនេះ ទំនងជាមនុស្ស
ស្រវឹងស្រាយ៉ាងជាលោកសង្ឃនោះផឹកស្រាទេដឹង បើដូច្នោះ
គួរអញលបទៅមើលឲ្យដាក់ច្បាស់ ទោះវាឆ្កួតឬឈឺចាប់យ៉ាង
ណាក៏តាមចុះ អញប្រថុយលបមើលគិតហើយក៏ដើរលបចូល
ទៅដល់ប្របជញ្ជាំងរោង ហើយលួចបើកស្លឹកត្នោត ដែលបាំង
នោះគន់មើលទៅក្នុងរោង ក៏ឃើញចៅពាលទាំង៤នាក់អង្គុយ
ដឹកង់គ្នាស៊ីបាយផឹកស្រាដោយអំពើពាល ។ ចៅសនឃើញច្បា
ស់ហើយក៏នឹកថា យីអាដែងអស់ទាំងនេះផឹកស្រាស៊ីបាយល្ងាចទេ
តើ ពុទ្ធោៗ ឱ ម៉ែឪអញទៅជឿអាពួកនេះឆ្កួតទទេ ទាំងអ្នក
ស្រុកក៏ជឿចុះចូលវាឲ្យវាបញ្ឆោតអស់ខ្លួនមែនហើយ បើ
ដូច្នោះគួរអញទៅប្រាប់ម៉ែឪឲ្យគាត់បានដឹងផងចុះ គិតហើយ
ក៏ដើរថយចេញម្នីម្នា រត់ត្រង់ទៅផ្ទះ បានឃើញម្ដាយនៅលើ
ផ្ទះ ចៅសនក៏ប្រាប់ថាម៉ែៗ ម៉ែឯងទៅជឿអីលោកសង្ឃធុត
ង្គនោះ មិនពិតជាលោកសង្ឃល្អទេវាក្លែងក្លាយទេម៉ែ ខ្ញុំបាន
ឃើញវាផឹកស្រា ស៊ីបាយល្ងាចអំបាញ់មិញនេះឯង ។



ឯនាងជាម្ដាយបានឮពាក្យកូនប្រាប់ដូច្នោះហើយក៏ពុំមានសតិ
សម្បជញ្ញៈ នឹងត្រិះរិះឲ្យច្បាស់លាស់ដោយជឿពាក្យតាថេន
ថា នរណាកាត់សីមាចូលក្នុងរោងពិធីលោក អ្នកនោះនឹងឆ្កួតប្រា
កដទើបកើតភិតភ័យតក្កមាហើយសួរថា "ចៅសនឯងចូលទៅ
ក្នុងរោងពិធីលោកឬអី?" ។ ចៅសនថា "បាទខ្ញុំបាទលួចលបចូល
ទៅឃើញ វាកំពុងតែផឹកស៊ីទាំង៤ នាក់ណ៎ាម៉ែ" ។ ម្ដាយថា "ឱ
កូនអើយ លោកបានហាមទាំងអស់គ្នាថា កុំឲ្យនរណាចូលទៅក្នុង
សីមារោងពិធីលោក ឥឡូវកូនឯងចូលទៅនោះ ត្រូវដូចលោក
ថាអ្នកណាចូលហើយអ្នកនោះនឹងឆ្កួតមិនខាន ឥឡូវឯងឆ្កួតហើ
យ តើកូនគួរអីទៅថាលោកសង្ឃផឹកស្រានោះ លោកជាអ្នក
ដើរធុតង្គវិសេសណាស់" ។ ចៅសនប្រកែកថា "ម៉ែឯងមិនជឿ
ខ្ញុំឬ ខ្ញុំបានឃើញច្បាស់នឹងភ្នែកហើយអាដែងទាំង៤នាក់នោះ
វាមកក្លែងបញ្ឆោតគេយកលាភទេ អ្នកណាទៅជឿវាក៏គង់នឹង
ខូចខ្លួន" ។ ឯនាងម្ដាយមិនស្ដាប់ ចេះតែថា អាឯងទៅចូលក្នុងសី
មាលោក វាឆ្កួតមែនហើយ ។ ឯបណ្ដាពួកញាតិនៅជិតខាង បាន
ឮចៅសននឹងម្ដាយប្រកែកគ្នាដូច្នោះហើយសឹងឆោឡោឡើង
ទៅសួរថា ម្ដេចចៅសនវាចូលទៅក្នុងសីមាលោកនោះឬអី?

នាងម្ដាយក៏ប្រាប់ទៅថាអើឯងអើយ វាចូលទៅក្នុងសីមាលោក ឥឡូវវាឆ្កួតវិវណាស់ទៅតាំងតែដេវលោកសង្ឃនេះផ្សេងៗ។

ឯពួកញាតិក៏នាំគ្នាស្ដីបន្ទោសចៅសន ហើយថាឆ្កួតមែនហើយធ្វើម្ដេចនឹងរកគ្រូឯណានឹងមើលបាន។ ឯចៅសនឮពួកញាតិបន្ទោសដូច្នោះហើយ ក៏ខឹងណាស់តាំងដេវដាសពាលទៅដល់ប្រកែកនឹងគេមិនឈ្នះ វាក៏យំផងព្រោះដោយសារក្មេង ឯពួកញាតិក៏រឹតតែជឿថា ចៅសនឆ្កួតមែនគឺពីដើមគ្រាន់តែថាលោសង្ឃផឹកស្រា ឥឡូវវិវខ្លាំងតាំងយំដេវគេឯងតែផ្ដាស មិនស្គាល់ចាស់ក្មេងផង ឯនាងជាម្ដាយនោះក៏ភិតភ័យ ទើបរត់ទៅឯរោងពិធីតាថេន ដល់ហើយស្រែកហៅទៅថា "ឱករុណាម្ចាស់ សូមមេត្តាប្រោសសត្វ សូមទាននិមន្តចេញមកខាងក្រៅរោងសិន ត្បិតសត្វកើតវិបត្តិហើយ ព្រះគុណម្ចាស់"។ ឯតាថេនឮនាងសិកានិមន្តឲ្យចេញដូច្នោះ ក៏ស្ទុះម្នីម្នាជូតមាត់ជូតកស្អាតហើយតាំងគ្រងចីវរជាបរិមណ្ឌលពាក់ផ្គាំ កាន់ឈើច្រត់ដើរលបៗចេញមកក្រៅហើយសួរ "កើតអីញោមបានជាភិតភ័យរលះរលាំងយ៉ាងនេះ"។ នាងសិកានោះ ក៏អង្គុយលុតជង្គង់ប្រណម្យដៃទូលថា "ករណាម្ចាស់ ឥឡូវនេះចៅសនកូនខ្ញុំករុណាវាចូល



មកក្នុងសីមាលោកម្ចាស់ ឥឡូវកើតវិវទៅជាឆ្កួតពុំដឹងអី ចេះតែស្រែកយំដេវគេឯងពាស ទៅដេវត្រូវទាំងលោកម្ចាស់ផង"។

តាថេនឆ្លើយថា "ញោម អាចក្ដីបានហាមហើយថាកុំឲ្យប្រហែសឲ្យហាមកូនហាមចៅកុំឲ្យវាចូលមកក្នុងសីមាពិធីនេះ ក្រែងវាកើតហេតុ ឥឡូវមែនៗ ដូចពាក្យអាចក្ដីថា ចុះឥឡូវនេះវានៅឯណាកូនញោមនោះ"។ "ករុណាម្ចាស់វានៅឯផ្ទះខ្ញុំករុណាឯនោះ"។ "អើបើដូច្នោះញោមទៅនាំខ្លួនវាមកឯរោងពិធីនេះ "អាចក្ដីនឹងមើលរោគឆ្កួតនោះណា៎ញោម នែញោមពាក្យចាស់លោលថា បន្លាមុតតោងយកបន្លាដោះ ទឹកចូលត្រចៀកតោងយកទឹកចាក់ រោគឆ្កួតកើតមកពីរោងពិធី តោងមកមើលរក្សាឯរោងពិធីទើបសះស្បើយបាន"។ ឯនាងសិកានោះក៏សំពះលាតាថេនវិលទៅពឹងបងប្អូនប្រុសៗ ៣ ៤ នាក់ឲ្យជួយចាប់យកខ្លួនចៅសនមកប្រគល់ឲ្យតាថេន។ ឯចៅសននោះត្រូវគេមកចាប់ដឹកនាំទៅដូច្នោះ ក៏រឹតតែខឹងនឹងពួកញាតិ តាំងបម្រះនទៀលដេវគេដេវឯង ហើយយំទៅតាមភាសាក្មេង តែធន់ពុំបាននឹងកម្លាំងមនុស្សចាស់គេក៏នាំគ្នាចាប់សែងពនាំទៅដល់

រោងពិធីនោះៗឯតាថេនក៏បបួលគ្នាទាំង៣ នាក់ចេញមកក្រៅ រោងហើយទទួលយកចៅសនទៅក្នុងរោងតាថេនៗ ក៏ប្រាប់ទៅ ថា ញោមទាំងអស់គ្នាសុទ្ធតែជាអ្នកមានគ្រោះនឹងនៅជិតរោង ពិធីនេះពុំបាន ក្រែងខ្មោចព្រាយអស់នោះវាចូលរូប អាត្មានឹង ស្រោចទឹកបន្ដចៅសនហើយ ខ្មោចដែលនៅក្នុងរូបចៅសន វា នឹងស្រែកជាខ្លាំងពុំខាន បើដូច្នោះចូរញាតិញោមទាំងអស់គ្នា ចៀសចេញទៅផ្ទះវិញឲ្យឆាប់ កុំនៅយូរក្រែងខ្មោចវាចូល ឯរូបចៅសននេះមិនអីទេ តែស្អែកខានស្អែកគង់នឹងជាមិនខាន ៗ ឯពួកញាតិចៅសនឮតាថេនថាដូច្នោះ ក៏នាំគ្នាសំពះលាលោក តាថេនវិលទៅផ្ទះទីទៃៗ ទៅៗ ឯតាថេនចូលទៅក្នុងរោងពិធី ហើយឲ្យគ្នា៣ នាក់នោះចងចៅសនខ្ជាប់នឹងសសររោង តាំង កាន់រំពាត់ផ្តៅទាំង៤ នាក់ហើយកំហែងសួរចៅសនថាអើអាសន អាឯងថា "ឃើញអញផឹកស្រាមែន ឬដូចម្ដេច? ចៅសនឆ្លើយ ថា "អើមែន ខ្ញុំឃើញលោកតាឯងផឹកស្រា ស៊ីបាយល្ងាចប្រាកដ ទាំង៤ នាក់"ៗ ពួកទាំងនោះក៏កើតទោសោ ហើយវាយចៅសន ៤ ៥ រំពាត់ចៅសនក៏ស្រែកយំដោយសំឡេងខ្លាំងៗ ទាំង៤នាក់ ក៏សាកសួរទៀតថា "ដូម្ដេចអាសនឯងថា ពួកយើងផឹកស្រាមែន



ឬដូចម្ដេច? ចៅសនថា "អើឯងផឹកស្រាមែនអញឃើញ ច្បាស់នឹងភ្នែកអញហើយ"ៗ អា៤នាក់ក៏រឹតតែវាយខ្លាំងលើស មុនៗ ចៅសនបាននូវសេចក្ដីវេទនា ឈឺចាប់ពនិពេកណាស់ ដល់ ក្រោយទើបគិតថា ឱអញនេះជាមនុស្សក្មេងម្នាក់ឯង គេឆ្កួត ពេញស្រុកទៅហើយ តែឯងមិនធ្វើឆ្កួតតាមគេនោះអាដែង ពួកពាលនេះវានឹងវាយអញដល់សេចក្ដីស្លាប់មិនខានឡើយ"ៗ

ណ្ហើយចុះតោងធ្វើជាឆ្កួតតាមវាទៅចុះទើបរក្សាខ្លួនសុខ បាន ចៅសនគិតដូច្នោះហើយទើបលើកដៃសំពះតាថេន ហើយ សាសព្ទប្រាប់ថា "ករុណាម្ចាស់ ខ្ញុំព្រះករុណានេះឆ្កួតមិនដឹងខ្លួន មិនដឹងប្រាណទេព្រះគុណ" បានជាថាព្រះគុណផឹកស្រានោះ គឺ ព្រះគុណពុំមែនឆាន់ស្រាទេ ខ្ញុំឆ្កួតមែនហើយ ឥឡូវខ្ញុំដឹងខ្លួនជា សះស្បើយហើយ រាងចាលហើយពីនេះទៅទៀត ខ្ញុំមិនថាព្រះ គុណផឹកស្រាទេទាន"ៗ តាថេនថា "អើបើឯងលែងថាអញផឹក ស្រា រាងចាលហើយអញក៏លែងវាយឯងតែត្រឹមនេះ"ៗ "ករុណា ខ្ញុំព្រះករុណាលែងថាព្រះគុណឆាន់ស្រាហើយ អំពីថ្ងៃ នេះតទៅ ករុណាម្ចាស់"ៗ "អើបើមែនដូច្នោះអញក៏លែងវាយ ឯង បើឯងនៅតែថាអញៗ ក៏វាយឯងទាល់តែស្លាប់"ៗថាហើយ

តាថេនក៏ឲ្យស្រាយចំណងចៅសនឃាត់ខាំងចៅសនមិនឲ្យចេញក្រៅរោង។ ឯចៅសនសោតទាស់ចំណេះ ក៏នៅបំរើអា៤នាក់នោះទៅតាមអធ្យាយស្រ័យ លុះថ្ងៃគំរប់៧ ជាពេលយប់ស្ងាត់ចៅសនក៏ដេកលក់ទៅ។ ឯចៅពាល៤នាក់នោះតាំងរើគ្រឿងកំណល់ពិធីយកប្រាក់ យកសំពត់ ផ្តិល ជើងពាន វេចជាសម្ពាយហើយក៏នាំគ្នាលបរត់ចេញចាកស្រុកនោះទៅនាក់ស្រុកដទៃ។ លុះវេលាព្រឹកចៅសនភ្ញាក់ឡើង ស្រាប់តែស្ងាត់ឈឹងទាំងរោងមើលទៅគ្រឿងតាំងពិធីនោះ ក៏បាត់អស់រលីងគ្មានសល់ដល់តិចឡើយ ចៅសនក៏ដឹងថា តាថេនលួចរបស់ទ្រព្យរត់ទៅអស់ហើយ ទើបចៅសនដើរចេញចាករោងចូលទៅផ្ទះអាត្មា។ ឯបណ្ដាញាតិមិត្តឃើញចៅសនដើរមកដូច្នោះហើយ ក៏សួរថា "ដូចម្ដេចទៅជីសនអើយរោគនោះបានស្រាកស្រាល ធូរខ្លួនប្រាណខ្លះហើយឬដូចម្ដេចទៅ"។ ចៅសនក៏តបថា "នៅឡើយទេតែថាឥឡូវនេះអំពើចំកួតនោះ វានៅលើអ្នកស្រុកទាំងអស់គ្នា អើឯងជាៗសោះ គេឆ្កួតពេញទាំងស្រុក ក៏ត្រឡប់ថាឯងឆ្កួតវិញ អើមីងមាយាយតាទាំងឯងស់គ្នាទៅជឿអាមនុស្សពាលនោះទុកជាគ្រូថា លោកធុតង្គរុក្ខមូលវិសេសណាស់ ឥឡូវ



គ្រឿងប្រដាប់ដែលតាំងពិធីព្លីកានោះ លោកធុតង្គទោះបន្លុងឆោកយកទៅអស់ហើយឲ្យអញ្ជើញទៅមើលចុះ ថាហើយចៅសនក៏ដើរត្រង់ទៅផ្ទះ។

ឯបណ្ដាលអ្នកស្រុងបានឮចៅសនថាដូច្នោះហើយខ្លះក៏សង្ស័យថា ក្រែងពិតដូចពាក្យចៅសនថាឬទើបនាំគ្នាទៅឯរោងពិធីស្រាប់តែឃើញស្ងាត់ឈឹងសូន្យក៏ចូលទៅរោង យល់របស់ទ្រព្យខ្លួននោះវិនាសអស់ទៅ ដោយដៃមនុស្សពាលទាំង៤នាក់នោះឯង ហើយទើបនាំគ្នាមកផ្ទះទីទៃៗ កើតសេចក្ដីវិប្បដិសារីរលឹកទោសអាត្មា ឃើញថាជាមនុស្សឥតបញ្ញា ទៅជឿពាលឲ្យវាបញ្ឆោតបាន គឺខ្លួនឆ្កួតប្រាកដចៅសនគ្នាជាសោះក៏នាំគ្នាជឿថាឆ្កួតវិញ។

ចប់និទានតាថេនតែប៉ុណ្ណោះ។